# កម្ពុជា:  អំពើហិង្សាប្រឆាំងនឹងស្ត្រីភេទ  ឆ្នាំ២០០៦

**A LICADHO Report**
**January 2006**

សម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស  លីកាដូ

**LICADHO**

CAMBODIAN LEAGUE FOR THE PROMOTION
AND DEFENCE OF HUMAN RIGHTS

# សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស (លីកាដូ)

**លីកាដូ គឺជាអង្គការមិនមែនរដ្ឋាភិបាលធ្វើការផ្នែកសិទ្ធិមនុស្សកម្ពុជា ។ អង្គការនេះត្រូវបានបង្កើតឡើងតាំងពីឆ្នាំ១៩៩២ ហើយជាអង្គការលេចធ្លោមួយក្នុងកិច្ចខិតខំប្រឹងប្រែងការពារសិទ្ធិមនុស្ស និងលើកស្ទួយការគោរពសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដោយរាជរដ្ឋាភិបាល និងស្ថាប័ននានានៅកម្ពុជា ។ ដើម្បីរក្សានូវសមិទ្ធិផលពីអតីតកាលរបស់ខ្លួន លីកាដូនៅតែបន្តជាអ្នកតស៊ូមតិសំរាប់ប្រជាពលរដ្ឋគ្រប់រូប និងជាអ្នកតាមឃ្លាំមើលរាជរដ្ឋាភិបាលតាមរយៈកម្មវិធីសិទ្ធិមនុស្សជាច្រើនពីការិយាល័យ កណ្តាលភ្នំពេញ និងសាខារបស់ខ្លួនទូទាំង១២ខេត្ត-ក្រុង ។**

**អង្គការលីកាដូបន្តសកម្មភាពរបស់ខ្លួនតាមរយៈការិយាល័យកម្មវិធី ៦ ដូចខាងក្រោម:**

- ការិយាល័យអប់រំសិទ្ធិមនុស្សផ្តល់វគ្គបណ្តុះបណ្តាលហ្វឹកហ្វឺនសិទ្ធិមនុស្សដល់ក្រុមគោលដៅ ដូចជាមន្ត្រីរដ្ឋាភិបាល សិស្សនិស្សិត ព្រះសង្ឃ និងបើកវគ្គផ្សព្វផ្សាយសិទ្ធិមនុស្ស ដល់សាធារណៈជនទូទៅ ។
- ការិយាល័យការពារសិទ្ធិមនុស្ស ស៊ើបអង្កេតករណីរំលោភសិទ្ធិមនុស្ស និងជួយជនរងគ្រោះអំពីកិច្ចការបណ្តឹងទាក់ទងផ្លូវច្បាប់ផ្សេងៗ។ ជាមួយគ្នានេះផងដែរ បុគ្គលិកលីកាដូដែលត្រូវបានហ្វឹកហ្វឺន បានឃ្លាំមើលស្ថានភាពពន្ធនាគារចំនួន១៨ និងដើម្បីធានាឱ្យពិរុទ្ធជនបានទទួលនូវតំណាងការពារតាមផ្លូវច្បាប់ត្រឹមត្រូវ ។
- ការិយាល័យពេទ្យ ផ្តល់ការព្យាបាលដល់ពិរុទ្ធជន/ទណ្ឌិត និងមន្ត្រីពន្ធនាគារក្នុងពន្ធនាគារ១៨ ព្រមទាំងជួយព្យាបាល និងបញ្ជូនទៅមន្ទីរពេទ្យចំពោះរងគ្រោះជនដែលរងគ្រោះដោយអំពើរំលោភសិទ្ធិមនុស្សនានា ។
- គំរោងប្រឆាំងអំពើទារុណកម្ម ផ្តល់សេវាស្តារលទ្ធភាពជាច្រើនដល់ជនរងគ្រោះដោយសារអំពើទារុណកម្ម និងធ្វើការតស៊ូមតិប្រឆាំងនឹងអំពើទារុណកម្មទៀតផង ។
- ការិយាល័យកុមារ ធ្វើការអប់រំសាធារណៈជនអំពីសិទ្ធិកុមារ បង្កើតបណ្តាញការពារកុមារនៅតាមមូលដ្ឋាននានា និងស៊ើបអង្កេតការរំលោភសិទ្ធិកុមារ ។
- ការិយាល័យសិទ្ធិស្ត្រី អប់រំសាធារណៈជនឱ្យយល់ដឹងអំពីសិទ្ធិស្ត្រី និងស៊ើបអង្កេតករណីរំលោភសិទ្ធិស្ត្រី ព្រមទាំងតស៊ូមតិឱ្យមានការផ្លាស់ប្តូរផ្នែកច្បាប់ និងសង្គម ។

**ចំពោះព័ត៌មានបន្ថែមសូមទាក់ទង :**

វេជ្ជ. **ពុង ឈីវកេក** ប្រធានអង្គការលីកាដូ
អាសយដ្ឋាន លីកាដូ (សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស)
ផ្ទះលេខ ១៦ ផ្លូវលេខ ៩៩
ភ្នំពេញ កម្ពុជា

ទូរស័ព្ទលេខ (៨៥៥) ២៣ ៣៦០ ៩៦៥ / ៣៦៤ ៩០១
ទូរសារ (៨៥៥) ២៣ ៣៦០ ៩៦៥ / ២១៧ ៦២៦

អ៊ីម៉េល contact@licadho.org
Web http://www.licadho.org/

# មាតិកា


អក្សរកាត់

របាយការណ៍សង្ខេប ............ ១

**I. បុព្វកថា** ............ **៣**

វិសាលភាពនៃរបាយការណ៍ ............ ៣

សេចក្តីថ្លែងអំណរគុណ ............ ៣

**II. អំពើហិង្សាក្នុងគ្រួសារ** ............ ៥

ស្ថានភាព ............ ៥

នីតិកម្ម ............ ៦

*និយមន័យនៃពាក្យអំពើហិង្សាក្នុងគ្រួសារ* ............ *៧*

*ច្បាប់ពាក់ព័ន្ធផ្សេងៗ* ............ *៧*

គោលនយោបាយរាជរដ្ឋាភិបាល ............ ៨

អំពើហិង្សាក្នុងគ្រួសារដែលពុំបានរាយការណ៍ ............ ៩

កង្វះចំណេះដឹង និងការអប់រំអំពីច្បាប់ និងអំពើហិង្សាក្នុងគ្រួសារ ............ ៩

ឧបសគ្គចម្បងៗ ............ ១០

*ការអនុវត្តន៍នីតិកម្ម* ............ *១០*

*រាជរដ្ឋាភិបាលខ្វះឆន្ទៈក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើហិង្សាក្នុងគ្រួសារ* ............ *១០*

*ភាពអន់ថយផ្នែកវប្បធម៌* ............ *១០*

អនុសាសន៍ ............ ១១

**III. អំពើរំលោភសេពសន្ថវៈ** ............ **១២**

ស្ថានភាព ............ ១២

នីតិកម្ម ............ ១៣

*និយមន័យនៃពាក្យរំលោភសេពសន្ថវៈ* ............ *១៣*

គោលនយោបាយ ............ ១៣

ករណីរំលោភសេពសន្ថវៈដែលពុំបានរាយការណ៍ ............ ១៤

ឥរិយាបទវប្បធម៌ និងសង្គមកម្ពុជា ............ ១៥

ឧបសគ្គចម្បងៗ ............ ១៦

*ភាពខ្វះចន្លោះនៃមាត្រាចែងអំពើរំលោភសេពសន្ថវៈក្នុងនីតិកម្មបច្ចុប្បន្ន* ............ *១៦*

*ការបកស្រាយច្បាប់ខុសដោយចៅក្រម និងមេធាវីនានា* ..... *១៧*
*និទណ្ឌភាព* ..... *១៨*
*អំពើពុករលួយ* ..... *១៨*
*ការសងសំណងរដ្ឋប្បវេណីខុសច្បាប់* ..... *១៨*
អនុសាសន៍ ..... ១៩
**IV. អំពើជួញដូរស្ត្រី** ..... **២១**
នីតិកម្ម ..... ២២
និយមន័យនៃពាក្យជួញដូរមនុស្ស ..... ២២
សេចក្តីព្រាងច្បាប់ប្រឆាំងនឹងអំពើជួញដូរមនុស្ស ..... ២៣
គោលនយោបាយ ..... ២៣
ផលប៉ះពាល់នៃសង្គមក្រោយជម្លោះ ..... ២៣
ភាពក្រីក្រ និងទេសន្តប្រវេសន៍ ..... ២៤
អំពើពេស្យាចារ ..... ២៥
ឧបសគ្គចម្បងៗ ..... ២៦
*ការរំលោភច្បាប់អន្តោប្រវេសន៍* ..... *២៦*
*កង្វះខាតច្បាប់ការពារ* ..... *២៧*
*កង្វះការអនុវត្តន៍ច្បាប់ និងនិទណ្ឌភាព* ..... *២៧*
*កង្វះវិធានការមាតុភូមិនិវត្តន៍ សមាហរណ្ណកម្ម និងស្តារឡើងវិញ* ..... *២៨*
អនុសាសន៍ ..... ២៨
**សេចក្តីសន្និដ្ឋាន** ..... **២៩**
នីតិកម្ម ..... ២៩
ឥរិយាបទសង្គម និងការអប់រំ ..... ២៩

# អក្សរកាត់

| | |
|---|---|
| **CAMBOW** | គណៈកម្មធិការស្ត្រីកម្ពុជា |
| **CEDAW** | អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទំរង់នៃអំពើរើសអើងចំពោះនារីភេទ |
| **CNCW** | ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី |
| **MOWA** | ក្រសួងកិច្ចការនារី |
| **NGO** | អង្គការមិនមែនរដ្ឋាភិបាល |
| **RGC** | រាជរដ្ឋាភិបាលកម្ពុជា |
| **STATE REPORT** | របាយការណ៍បឋម ទី២ និងទី៣ ស្តីពីការអនុវត្តន៍ CEDAW |
| **UN CEDAW Committee** | គណៈកម្មាធិការអង្គការសហប្រជាជាតិដើម្បីលុបបំបាត់រាល់ទំរង់នៃអំពើរើសអើងចំពោះនារីភេទ |
| **UNTAC Criminal Code** | អាជ្ញាធរបណ្តោះអាសន្នអង្គការសហប្រជាជាតិនៅកម្ពុជា-មាត្រាច្បាប់ទាក់ទងទៅនឹងតុលាការ និងច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីអនុវត្តនៅកម្ពុជាក្នុងសម័យអន្តរកាល ។ |

# របាយការណ៍សង្ខេប

ខណៈដែលអំពើហិង្សាលើស្ត្រីនៅកម្ពុជា ជាបញ្ហាដ៏លំបាកមួយក្នុងការកំណត់បរិមាណឱ្យបានត្រឹមត្រូវនោះ ក៏វានៅតែមានលក្ខណៈច្បាស់ណាស់ថា ជាបញ្ហាធ្ងន់ធ្ងរ ហើយបរិមាណនៃការរំលោភក៏កំពុងតែកើនឡើងជាលំដាប់ឥតឈប់ឈររួមមានករណីអំពើហិង្សាក្នុងគ្រួសារ រំលោភសេពសន្ថវៈ និងអំពើជួញដូរជាដើម ។ ទោះបីជាកម្ពុជាបច្ចុប្បន្នកំពុងតែទទួលស្គាល់អំពីសារៈសំខាន់នៃបញ្ហាទាំងនេះក៏ដោយ ក៏ទំហំនៃសុឆន្ទៈរបស់រាជរដ្ឋាភិបាលក្នុងការអប់រំតុលាការ នគរបាល និងសាធារណៈជនឱ្យយល់ដឹងអំពីបញ្ហានេះនៅមានកំរិតនៅឡើយ ។

កម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញា ស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនារីភេទ (CEDAW) នៅឆ្នាំ១៩៩២ ហើយចាប់តាំងពីពេលនោះមកពុំទាន់មានការចាត់វិធានការឱ្យគ្រប់គ្រាន់ដោយរាជរដ្ឋាភិបាលដើម្បីអនុវត្តគោលការណ៍នានាដែលមានចែងក្នុងអនុសញ្ញានោះនៅឡើយទេ។ ចំណុចមួយដែលគួរឱ្យកត់សំគាល់ គឺរាជរដ្ឋាភិបាលបានអនុម័តច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ កាលពីខែកញ្ញា ឆ្នាំ២០០៥ កន្លងទៅថ្មីៗនេះ ហើយសេចក្តីព្រៀងច្បាប់ស្តីពីអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទបច្ចុប្បន្ននេះក៏កំពុងត្រូវបានពិនិត្យសារឡើងវិញដោយក្រុមអ្នកតាក់តែងច្បាប់ ។ ទោះជាយ៉ាងនេះក៏ដោយក៏ការរីកចំរើនក្នុងការកាត់បន្ថយ និងលុបបំបាត់អំពើហិង្សាលើស្ត្រីចាប់តាំងពីឆ្នាំ១៩៩២ នៅតែមានល្បឿនយឺត និងជារឿយៗមិនទាន់គ្រប់គ្រាន់នៅឡើយ ។

រាជរដ្ឋាភិបាលកម្ពុជាក៏ទើបតែទទួលស្គាល់នូវភាពធ្ងន់ធ្ងរនៃបញ្ហាអំពើហិង្សាក្នុងគ្រួសារនៅកម្ពុជាថ្មីៗនេះដែរ ដោយបានអនុម័តនូវច្បាប់ថ្មីមួយ ។ ប៉ុន្តែជំនឿសង្គម និងវប្បធម៌ដែលបានកប់យ៉ាងជ្រៅនៅក្នុងសង្គមកម្ពុជាកំពុងបន្តបិទបាំងនូវវត្តមានការទទួលស្គាល់ និងការរាយការណ៍នូវអំពើហិង្សាក្នុងគ្រួសារ ដែលបណ្តាលឱ្យកាន់តែមានការលំបាកក្នុងការទទួលស្គាល់ថា ជាបញ្ហាធ្ងន់ធ្ងរដែលមន្ត្រីនគរបាល និងតុលាការអាច និងត្រូវតែធ្វើអន្តរាគមន៍ទប់ទល់ ដើម្បីជួយជនរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារនេះ។

រាជរដ្ឋាភិបាលកម្ពុជាក៏បានអនុវត្តចំពោះបញ្ហារំលោភសេពសន្ថវៈដោយច្បាប់ ដែលប្រកបដោយភាពស្រពិចស្រពិលស្រដៀងគ្នានេះដែរ ហើយឧបសគ្គនានាមានដូចជា ការបកស្រាយច្បាប់ និទ្ទណ្ឌភាពអំពើពុករលួយ និងការសងសំណងរដ្ឋប្បវេណីក្រៅផ្លូវការ ដែលធ្វើឱ្យបទឧក្រិដ្ឋមានលក្ខណៈកាន់តែធ្ងន់ធ្ងរថែមទៀត បន្សល់ទុកជនរងគ្រោះឯកកោរដោយពុំមានការជួយឧបត្ថមគាំទ្រ ព្រមទាំងអនុញ្ញាត

ឱ្យជនល្មើសប្រព្រឹត្តម្តងហើយម្តងទៀតដោយគ្មានទណ្ឌកម្មឡើយ ។ នៅក្នុងវប្បធម៌មួយដែលអំពើរំលោភសេពសន្ថវៈច្រើនតែត្រូវបានគេគិតថាជាអំពើមួយដែលអាចសម្រុះសម្រួលបាន ឬជាកំហុសរបស់ជនរងគ្រោះនោះ តម្រូវការអប់រំលើកស្ទួយការគោរពស្ត្រីទាំងឡាយ និងការបកស្រាយច្បាប់ពាក់ព័ន្ធនឹងបញ្ហារំលោភសេពសន្ថវៈឱ្យត្រឹមត្រូវនោះ គឺជាតម្រូវការចាំបាច់តែមួយគត់ ។

អំពើជួញដូរមនុស្សបានក្លាយទៅជាបញ្ហាដ៏ធំមួយនៅកម្ពុជា ក្នុងវិសាលភាពដែលបទឧក្រិដ្ឋនេះបានរាលដាលយ៉ាងទូលំទូលាយ ដែលបច្ចុប្បន្ននេះកំពុងតែត្រូវបានទទួលស្គាល់ជាអន្តរជាតិ ។ រាជរដ្ឋាភិបាលកម្ពុជាបានទទួលស្គាល់ភាពធ្ងន់ធ្ងរនៃបញ្ហានេះ និងកំពុងតែចាប់ផ្តើមចាត់វិធានការនានាដើម្បីប្រយុទ្ធប្រឆាំងនឹងបញ្ហានេះ ។ ប៉ុន្តែការយឺតយ៉ាវក្នុងការអនុម័តសេចក្តីព្រាងច្បាប់ស្តីពីការជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ ព្រមទាំងកង្វះលទ្ធភាពក្នុងការអនុវត្តន៍ច្បាប់ដែលមានស្រាប់ដោយនគរបាល និងតុលាការនោះជាការបញ្ជាក់នូវភាពខ្វះចន្លោះនៃការចាត់វិធានការរបស់រាជរដ្ឋាភិបាលក្នុងការដោះស្រាយបញ្ហានេះឱ្យបានសមរម្យ ។

រាជរដ្ឋាភិបាលកម្ពុជាត្រូវអនុម័តជាបន្ទាន់នូវច្បាប់ទាំងឡាយណា ដែលទទួលស្គាល់អំពើហិង្សាលើស្ត្រីជាបទឧក្រិដ្ឋធ្ងន់ធ្ងរនៅកម្ពុជា និងត្រូវអនុវត្តច្បាប់ និងវិធានការទាំងនេះដើម្បីធានាកម្ពុជាឱ្យសម្រេចបានកាតព្វកិច្ចរបស់ខ្លួនតាមអនុសញ្ញា ស្តីពីការលុបបំបាត់រាល់ទំរង់នៃការរើសអើងប្រឆាំងស្ត្រីភេទ ។ យុទ្ធនាការអប់រំ និងការលើកកំពស់ការយល់ដឹងថែមទៀតជាការលើកស្ទួយដល់សិទ្ធិស្ត្រីនៅក្នុងសង្គម កន្លែងធ្វើការ នៅគេហដ្ឋាន និងនៅក្នុងគ្រួសារដែលត្រូវតែអនុវត្ត ប្រសិនបើអំពើហិង្សាមកលើស្ត្រីត្រូវបានទទួលស្គាល់ជាដាច់ គិតថាវាជាទម្លាប់វប្បធម៌ ។

# I. បុព្វកថា

អំពើហិង្សាលើស្ត្រីនៅកម្ពុជា ជាអំពើធ្ងន់ធ្ងរ និងប្រកបដោយល្បិចកលជាទីបំផុត ។ ពុំមានស្ថិតិណាមួយអាចកំណត់ពីចំនួនជាក់លាក់ថា មានស្ត្រីប៉ុន្មាននាក់នៅកម្ពុជារងគ្រោះដោយអំពើហិង្សានេះឡើយ ។ ប៉ុន្តែយើងអាចបានដឹងច្បាស់ថាទម្រង់ហិង្សាដ៏អាក្រក់បំផុតត្រូវបានប្រព្រឹត្តិមកលើស្ត្រី(ដូចជាអំពើហិង្សាក្នុងគ្រួសារ រំលោភសេពសន្ថវៈ និងអំពើជួញដូរស្ត្រីជាដើម) កើតឡើងជាប្រចាំនៅកម្ពុជា ។

កំណើនបរិមាណអំពើហិង្សាលើស្ត្រីត្រូវបានរាយការណ៍ និងក្នុងខណៈដែលបច្ចុប្បន្ននេះមានច្បាប់គ្រប់គ្រាន់ដើម្បីការពារស្ត្រីពីបទឧក្រិដ្ឋប្រភេទនេះក្តី
ប៉ុន្តែរាជរដ្ឋាភិបាលបែរជាពុំបានចាត់វិធានការឱ្យបាន គ្រប់គ្រាន់ដើម្បីប្រយុទ្ធប្រឆាំងនឹងបញ្ហាលើស្ត្រី ។ ឥរិយាបទសង្គម និងវប្បធម៌ចំពោះហិង្សាលើស្ត្រី វប្បធម៌និទ្ទណ្ឌភាពអំពើអយុត្តិធម៌ផ្នែកច្បាប់ និងតុលាការទាំងអស់នេះជាការរួមចំណែកធ្វើឱ្យស្ត្រីនៅ
កម្ពុជាកាន់តែរងគ្រោះខ្លាំងឡើងៗដោយអំពើហិង្សា ។

## វិសាលភាពនៃរបាយការណ៍

របាយការណ៍នេះមានគោលបំណងក្នុងការផ្តល់នូវការវិភាគជាក់លាក់នៃទំរង់ហិង្សាទាំង ៣ លើស្ត្រីភេទ ដែលទម្រង់ទាំងនោះគឺអំពើហិង្សាក្នុងគ្រួសារ រំលោភសេពសន្ថវៈ និងអំពើជួញដូរស្ត្រី ។ ជាពិសេស របាយការណ៍នេះបានស្រាវជ្រាវរកឃើញនូវស្ថានភាពហិង្សានីមួយៗនៅកម្ពុជា និងផ្តល់នូវការវិភាគចំពោះការឆ្លើយតបរបស់រាជរដ្ឋាភិបាលចំពោះបញ្ហានេះ ។ ការវិភាគនឹងផ្តោតលើច្បាប់នានាដែលការពារស្ត្រី និងឧបសគ្គធំៗដែលមាននៅក្នុងការអនុវត្តន៍ និង/ឬការកែទម្រង់ច្បាប់ ។

## សេចក្តីថ្លែងអំណរគុណ

របាយការណ៍នេះត្រូវបានចងក្រងឡើងដោយមានការជួយឧបត្ថម្ភគាំទ្រពីសំណាក់សមាជិកនានានៃគណៈកម្មាធិការស្ត្រីកម្ពុជា (ឃែមបូវ) [1] ដែលបានផ្តល់នូវព័ត៌មានស្ថិតិ និងសំណួរនានាមកលីកាដូ ។ ឃែមបូវ គឺជាគណៈកម្មាធិការចម្រុះដែលមានសមាជិក ៣៥ ជាអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការ

[1] ឃែមបូវត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០០០ ដោយមានការគាំទ្រ និងផ្តល់មូលនិធិដោយមូលនិធិអាស៊ី ។

ដើម្បីអភិវឌ្ឍន៍ និងបុព្វហេតុរបស់ស្ត្រីនៅកម្ពុជា។ គណៈកម្មាធិការចម្រុះនេះត្រូវបានចូលរួមពាក់ព័ន្ធក្នុង បញ្ហានានារបស់ស្ត្រី និងស្វះស្វែងដើម្បីឱ្យមានការលុបបំបាត់នូវច្បាប់ និងការអនុវត្តន៍ដែលប្រកបដោយការរើសអើងចំពោះស្ត្រី ជាពិសេសច្បាប់ទាំងឡាយ ដែលពាក់ព័ន្ធនឹងអំពើហិង្សាក្នុងគ្រួសារ និងអំពើជួញដូរស្ត្រី ។

របាយការណ៍សង្ខេប ដែលសង្ខេបចេញពីរបាយការណ៍នេះក៏ត្រូវបានដាក់ជូនទៅគណៈកម្មាធិការអង្គការសហប្រជាជាតិស្តីពីការលុបបំបាត់រាល់ទំរង់នៃការរើសអើងប្រឆាំងស្ត្រីភេទ ដែលហៅកាត់ថា (គណៈកម្មាធិការ CEDAW UN) ជាផ្នែកមួយនៃរបាយការណ៍ស្រមោលរបស់អង្គការមិនមែនរដ្ឋាភិបាលកម្ពុជា ។ របាយការណ៍ស្រមោលរបស់អង្គការ មិនមែនរដ្ឋាភិបាលកម្ពុជាត្រូវបានដាក់ជូនជារបាយការណ៍ស្របនឹងរបាយការណ៍រាជរដ្ឋាភិបាល ដែលជារបាយការណ៍បឋមដំណាក់កាលទី២ និងរបាយការណ៍ដំណាក់កាលទី៣ ស្តីពីការអនុវត្តន៍អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងស្ត្រីភេទហៅថា CEDAW (របាយការណ៍រដ្ឋ) ដែលរៀបចំដោយរាជរដ្ឋាភិបាលកម្ពុជាកាលពីខែតុលា ឆ្នាំ២០០៥កន្លងទៅ សំរាប់ធ្វើការត្រួតពិនិត្យក្នុងខែមករា ឆ្នាំ២០០៦ ។ ប្រទេសកម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងស្ត្រីភេទនៅឆ្នាំ១៩៩២ ដោយពុំមានថបនីយឡើយ (ការដកមាត្រាណាមួយចេញដោយមិនចង់អនុវត្ត) ហើយរបាយការណ៍នេះ គឺជារបាយការណ៍រដ្ឋជាផ្លូវការលើកដំបូងដែលរាជរដ្ឋាភិបាលកម្ពុជាបានដាក់ជូនទៅគណៈកម្មាធិការ CEDAW អង្គការសហប្រជាជាតិ ។

របាយការណ៍ស្រមោលរបស់អង្គការមិនមែនរដ្ឋាភិបាលកម្ពុជា ដែលដាក់ជូនទៅគណៈកម្មាធិការ CEDAW ត្រូវបានដាក់ជូនរួមគ្នាដោយគណៈកម្មាធិការពីរ គឺគណៈកម្មាធិការ ឃែមបូវ និងគណៈកម្មាធិការអង្គការមិនមែនរដ្ឋាភិបាលកម្ពុជាអំពី CEDAW កាលពីខែវិច្ឆិកា ឆ្នាំ២០០៥ កន្លងទៅនេះ ។

# II. អំពើហិង្សាក្នុងគ្រួសារ

## ស្ថានភាព

ដូចនៅក្នុងប្រទេសដទៃៗទៀតដែរ អំពើហិង្សាក្នុងគ្រួសារនៅកម្ពុជា គឺជាបញ្ហាដ៏ លំបាកមួយ ដោយវាបានធ្វើឱ្យជនរងគ្រោះមានស្លាកស្នាមទាំងលើរូបរាងកាយ ផ្លូវចិត្ត និងផ្លូវអារម្មណ៍ ។ ប៉ុន្តែនៅកម្ពុជា មិនដូចនៅប្រទេសនានាទេ កម្ពុជាមានក្រមសីលធម៌[២] មួយដែលហៅថា ***ច្បាប់ស្រី*** ដែលបានចែង ថា ស្ត្រីត្រូវតែបំរើ និងគោរពប្តីរបស់ខ្លួនគ្រប់ពេលវេលា ។ ការប្រៀនប្រដៅរបស់ច្បាប់ស្រីនោះ រួមមាន ដូចជា មិនឱ្យស្ត្រីនិយាយរឿងរ៉ាវរបស់ប្តីខ្លួនទៅប្រាប់ឱពុកម្តាយ ដែលគេគិតថា អាចបណ្តាលឱ្យមានជំលោះកើតឡើង ទូន្មានស្ត្រីមិនឱ្យដេកបែរខ្នងដាក់ប្តី មិនត្រូវទះក្បាលប្តីដោយពុំបានគោរពសុំទោសប្តីជាមុន ព្រមទាំងឱ្យស្ត្រីអត់ធ្មត់មិនតបតពេលប្តីកំពុងខឹង ។ វប្បធម៌ និងប្រពៃណីបានបង្គាប់ឱ្យស្ត្រីគ្រប់រូបខិតខំគោរពប្រតិបតិច្បាប់នេះឱ្យបានល្អនោះនឹងបានសុខ ។ ជាផលវិបាកដោយសារតែច្បាប់ក្បួននេះហើយទើបស្ត្រីកម្ពុជាដែលរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារមិនដែលហ៊ានលើកយកបញ្ហានេះម ក ពិភាក្សាជាមួយអ្នកក្រៅទេ ដោយជឿជាក់ថា វាជារឿងផ្ទៃក្នុងរបស់គ្រួសារដែលមិនគួរយកទៅប្រាប់អ្នក ដទៃឡើយ ។

ដោយបន្តប្រតិបត្តិតាមប្រពៃណីស្ងៀមស្ងាត់អំពីហិង្សាក្នុងគ្រួសាររបស់កម្ពុជានេះហើយ ទើបរបាយការណ៍[៣] មានពត៌មានតិចតួចបំផុតអំពីបញ្ហាហិង្សាលើស្ត្រីភេទនេះ ជាពិសេសអំពីបញ្ហាអំពើហិង្សាក្នុងគ្រួសារ ។

អំពើហិង្សាក្នុងគ្រួសារគឺជាកត្តាចម្បងមួយ ដែលរួមចំណែកឱ្យមានអសមភាពយេនឌ័រនៅកម្ពុជា ។ ដោយគ្មានតួលេខពិតប្រាកដអំពីចំនួនជនរងគ្រោះដោយអំពើនេះ យោងតាមការសិក្សាស្រាវជ្រាវអំពីប្រជាសាស្ត្រ និងសុខភាពកម្ពុជាកាលពីឆ្នាំ២០០០ កន្លងទៅបានឱ្យដឹងថា ២៣ ភាគរយនៃស្ត្រីដែលមានអាយុពី១៥ ទៅ ៤៩ ឆ្នាំ ដែលរៀបការហើយធ្លាប់បានទទួលរងនូវអំពើហិង្សាក្នុងគ្រួសាររបស់ពួកគេ ។ ចំណែកឯរបាយការណ៍មួយផ្សេងទៀត ស្តីពីអំពើហិង្សាក្នុងគ្រួសារដែលនឹងចេញផ្សាយពេលឆាប់ៗនេះ រៀបចំដោយក្រសួងកិច្ចការនារី (MOWA) ហើយដែលបានសិក្សាលើមនុស្ស ៣០០០ នាក់ ក្នុងខេត្តចំនួន

---

[2] ច្បាប់ស្រី គឺជាក្រមសីលធម៌ប្រពៃណីមួយសំរាប់ស្ត្រីកម្ពុជា ដែលត្រូវបានគោរពតៗគ្នាពីជំនាន់មួយទៅជំនាន់មួយទៀត ។

[3] របាយការណ៍រដ្ឋ : របាយការណ៍បឋម របាយការណ៍ទី២ និងរបាយការណ៍ទី៣
ស្តីពីការអនុវត្តន៍អនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃ ការរើសអើងប្រឆាំងស្ត្រីភេទនៅកម្ពុជា ខែតុលា ឆ្នាំ២០០៥ ។

១៣ អំពីឥរិយាបទចំពោះអំពើហិង្សាក្នុងគ្រួសារ[៤] ។ ហើយក្នុងចំណោមអ្នកដែលត្រូវបានសម្ភាសន៍ទាំងអស់មាន ៨០ ភាគរយនៃស្ត្រីបានឆ្លើយថា គេបានស្គាល់ស្វាមីម្នាក់ដែលបានប្រើអំពើហិង្សាលើរូបរាងកាយជាមួយនឹងប្រពន្ធគាត់[៥] ហើយមានស្ត្រី ២៥ ភាគរយទៀតដែលបាននិយាយថា ពួកគេបានទទួលរងការវាយដំលើរូបរាងកាយ ពីសំណាក់ប្តីរបស់ខ្លួន ។

មានកត្តាជាច្រើនដែលរួមចំណែកក្នុងការធ្វើឱ្យបញ្ហានេះកើនឡើងជាលំដាប់ ។ តាមការសិក្សាស្រាវជ្រាវមួយចំនួនបានបង្ហាញឱ្យដឹងថា ការកើនឡើងនៃភាពក្រីក្រក៏ជាកត្តាមួយបណ្តាលឱ្យមានកំណើនករណី អំពើហិង្សាក្នុងគ្រួសារនេះដែរ[៦] ។ បញ្ហានេះក៏អាចពាក់ព័ន្ធទៅនឹងការរងគ្រោះដោយសារសង្គ្រាមនៅកម្ពុជាជាងបីទសវត្សកន្លងទៅផងដែរ ដែលបានប្រែក្លាយអំពើហិង្សានានា ដែលធ្លាប់កើតកន្លងមកទៅជាបរិយាកាសហិង្សា[៧] ។

### ករណីអំពើហិង្សាក្នុងគ្រួសារដែលរាយការណ៍ដោយ លីកាដូ




*តួលេខឆ្នាំ ២០០៥ គិតពីខែមករា ដល់ កក្កដា ប៉ុណ្ណោះ*

## នីតិកម្ម

រហូតមកដល់ពេលថ្មីៗនេះ ឧបសគ្គចម្បងៗមួយចំនួន ដែលបង្ករការលំបាកដល់បញ្ហាអំពើហិង្សាក្នុងគ្រួសារនោះគឺបញ្ហាកង្វះការតស៊ូមតិផ្នែកច្បាប់ជាក់លាក់ ដើម្បីឱ្យមានកិច្ចការពារជនរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារនៅកម្ពុជា ។ កាលពីថ្ងៃទី១៦ កញ្ញា និងថ្ងៃទី២៩ កញ្ញា ឆ្នាំ២០០៥ កន្លងទៅរដ្ឋសភាជាតិ និងព្រឹទ្ធសភាបានអនុម័តច្បាប់ *ស្តីពីអំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ*

---

4 ហិង្សាលើស្ត្រី ភេទ : ការសិក្សាអំពីចំណេះដឹងជាមូលដ្ឋាន (ក្រសួងកិច្ចការនារី ភ្នំពេញ ឆ្នាំ២០០៥) ។

5 ឯកសារដដែល ទំព័រ ២៧ ។

6 មជ្ឈមណ្ឌលកម្ពុជាដើម្បីស្ត្រីមានវិបត្តិ — ជួយឱ្យស្ត្រីចេះជួយខ្លួនឯង (របាយការណ៍ប្រចាំឆ្នាំរបស់មជ្ឈមណ្ឌលកម្ពុជាដើម្បីស្ត្រីមានវិបត្តិ ខែមករា - ធ្នូ ២០០២)

7 របាយការណ៍សិទ្ធិស្ត្រីកម្ពុជា ឆ្នាំ ២០០៤ : របាយការណ៍សង្ខេបស្តីពីស្ថានភាពស្ត្រីនៅកម្ពុជា (លីកាដូ កក្កដា ឆ្នាំ២០០៤ ) ទំព័រ ៨ ។

ហើយព្រះមហាក្សត្រ ព្រះបាទ នរោត្តម សីហមុនី ក៏បានឡាយព្រះហស្ថលេខាលើច្បាប់នោះដែរ កាលពីថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៥ កន្លងទៅនេះ ។ ប៉ុន្តែ រហូតមកដល់ពេលសរសេររបាយការណ៍នេះ ច្បាប់នេះក៏នៅតែពុំទាន់ត្រូវបានអនុវត្តនៅឡើយនៅកម្ពុជា ។

ការអនុម័តច្បាប់នេះអាចចាត់ទុកថា ជានិមិត្តសញ្ញានៃការសន្យារបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីការពារជនរងគ្រោះ។ ប៉ុន្តែ ការពិតគឺនៅមានបញ្ហាសេសសល់មួយចំនួនចាប់តាំងពីបានផ្តល់សច្ចាប័ន លើអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទំរង់នៃការរើសអើងប្រឆាំងស្ត្រីភេទក្នុងឆ្នាំ១៩៩២នោះមក រដ្ឋាភិបាលត្រូវចំណាយពេល ១៣ឆ្នាំ ដើម្បីអនុម័តច្បាប់សិទ្ធិមនុស្សជាមូលដ្ឋាន ដែលមានសារសំខាន់ជាទីបំផុតក្នុងកិច្ចការពារសិទ្ធិរបស់ស្ត្រី ។

## *និយមន័យនៃពាក្យអំពើហិង្សាក្នុងគ្រួសារ*

មាត្រា ២ នៃច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ដែលទើបត្រូវបានអនុម័តថ្មីៗកន្លងទៅនេះ បានឱ្យនិយមន័យនៃពាក្យអំពើហិង្សាក្នុងគ្រួសារថា ជាហិង្សាដែលកើតឡើង និងកើតចំពោះ :

១. ប្តី ឬ ប្រពន្ធ

២. កូននៅក្នុងគ្រួសារ

៣. មនុស្សដែលរស់នៅក្រោមដំបូលផ្ទះ ហើយជាសមាជិកក្នុងបន្ទុកគ្រួសារនោះ ។

និយមន័យនេះបានពង្រីកវិសាលភាពនៃអំពើហិង្សាក្នុងគ្រួសារ ដោយបានបញ្ចូលនូវមនុស្សទាំងឡាយដែលរស់នៅក្នុងផ្ទះជាមួយ ។ ច្បាប់នេះបាននាំអំពើហិង្សាក្នុងគ្រួសារចូលទៅក្នុងឆាកថ្មីមួយ និងពុំមែនជារឿងផ្ទៃក្នុងនៃផ្ទះ និងគ្រួសារទៀតឡើយ ដែលអាចឱ្យស្ត្រីកម្ពុជាការពារខ្លួនគេបានយ៉ាងជាក់លាក់ពីអំពើហិង្សាក្នុងគ្រួសារ ។

## *ច្បាប់ពាក់ព័ន្ធផ្សេងៗ*

រដ្ឋធម្មនុញ្ញក៏បានចែងពីកិច្ចការពារជនរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារដែរ ដោយបានចែងដូចជា "សិទ្ធិរស់រានមានជីវិត សេរីភាព និងសន្តិសុខផ្ទាល់ខ្លួន"[៨] ហើយសិទ្ធិរស់រានមានជីវិត មានកិត្តិយស និងសេចក្តីថ្លៃថ្នូ[៩] ។

---

8 រដ្ឋធម្មនុញ្ញ មាត្រា ៣២ ។

9 រដ្ឋធម្មនុញ្ញ មាត្រា ៣៨ ។

អាជ្ញាធរអង្គការសហប្រជាជាតិបណ្ដោះអាសន្ននៅកម្ពុជា បានចែងនូវមាត្រាមួយចំនួនដែលទាក់ទងនឹងច្បាប់ព្រហ្មទណ្ឌ និងតុលាការ និងនីតិវិធីដែលអនុវត្តនៅកម្ពុជាក្នុងសម័យអ៊ុនតាក់ ដែលហៅថា (ច្បាប់ព្រហ្មទណ្ឌអន្តរកាល) បានកំណត់ថា អំពើរំលោភសេពសន្ថវៈ[10] បៀតបៀនកេរខ្មាស់[11] និងការវាយដំជាបទឧក្រិដ្ឋ ។

ច្បាប់ស្ដីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋក៏បានចាត់ទុកករណីរំលោភសេពសន្ថវៈជាបទក្រិដ្ឋដែរ[12] ។ ច្បាប់ទាំងនេះពួតផ្គុំរួមគ្នា គឺវាហួសពីគ្រប់គ្រាន់សំរាប់ការពារជនរងគ្រោះ ដោយអំពើហិង្សាក្នុងគ្រួសារ ព្រមទាំងអាចទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារមិនឱ្យកើតឡើងបានថែមទៀតផង។

ធាតុពិតគឺភាពខ្លាំងនៃច្បាប់ទាំងនេះ ត្រូវបានបំផ្លាញដោយកង្វះការអនុវត្តន៍នៅក្នុងបរិបទនៃប្រទេសនេះឯង ។ ត្រូវចំណាយពេលខ្លះដើម្បីវាយតម្លៃពីសារប្រយោជន៍នៃការអនុម័តច្បាប់ថ្មីស្ដីពីអំពើហិង្សាក្នុង គ្រួសារនេះ ។

## គោលនយោបាយរាជរដ្ឋាភិបាល

កម្មវិធីនារីរតនៈ II ដែលជាយុទ្ធសាស្ត្រ ៥ ឆ្នាំលើកទី២របស់ក្រសួងកិច្ចការនារី (MOWA) លើកឡើងអំពីបញ្ហាអំពើហិង្សាក្នុងគ្រួសារ[១៣] និងបានគូសបញ្ជាក់ពីតម្រូវការសំរាប់កិច្ចខិតខំប្រឹងប្រែងផ្នែកច្បាប់ និងគោលនយោបាយបន្តទៀត "ដើម្បីកាត់បន្ថយអំពើហិង្សាក្នុងគ្រួសារ[១៤] "។

របាយការណ៍របស់រដ្ឋបានធ្វើការកត់សំគាល់ថាការបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី (CNCW )[១៥] ក្នុងឆ្នាំ២០០១ គឺជាយន្តការសម្របសម្រួល និងផ្ដល់ប្រឹក្សាដល់រាជរដ្ឋាភិបាលអំពីបញ្ហានានាទាក់ទងនឹងការលើកស្ទួយស្ថានភាពតួនាទី និងសង្គមកិច្ចរបស់ស្ត្រីកម្ពុជាក្នុងគោលបំណងដើម្បីកាត់បន្ថយ និងលុបបំបាត់រាល់ទំរង់នៃការរើសអើងប្រឆាំងនឹងនារីភេទ ។

ដូច្នេះ កិច្ចខិតខំប្រឹងប្រែងតាមរយៈគោលនយោបាយទាំងនេះ ដោយរាជរដ្ឋាភិបាលកម្ពុជាក៏ មិនទាន់គ្រប់គ្រាន់នៅឡើយទេក្នុងការជួយ និងការពារជនរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារនេះ ។

---

[10] ច្បាប់ព្រហ្មទណ្ឌអន្តរកាល មាត្រា ៣៣ ។

[11] ច្បាប់ព្រហ្មទណ្ឌអន្តរកាល មាត្រា ៤២ ។

[12] ច្បាប់ស្ដីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ មាត្រា ៥ ។

[13] នារីរតនៈ II ទំព័រ ១០ ។

[14] Op Cit 4, P. 20.

[15] បង្កើតឡើងនៅឆ្នាំ២០០១ ។ រួមមានរដ្ឋលេខាធិការពីក្រសួងចំនួន ១៤ ដែលមានគោលការណ៍ទាក់ទងនឹងការតស៊ូមតិ ឃ្លាំមើល និងវាយតម្លៃច្បាប់បទបញ្ញត្តិ និងគោលនយោបាយនានារបស់រាជរដ្ឋាភិបាលអំពីទស្សនៈយែនឌ័រ ។

## អំពើហិង្សាក្នុងគ្រួសារដែលពុំបានរាយការណ៍

ជាអកុសលវប្បធម៌កម្ពុជាធ្វើឱ្យស្ត្រីទាំងឡាយមានការស្ទាក់ស្ទើរក្នុងការរាយការណ៍អំពីករណីហិង្សាក្នុងគ្រួសារ ។ ចាប់ពីឆ្នាំ២០០០ ដល់២០០៥ មានករណីអំពើហិង្សាក្នុងគ្រួសាររាប់ពាន់ករណីត្រូវបានរាយការណ៍[១៦] ។ ប៉ុន្តែ តួលេខដែលបានរាយការណ៍ទាំងនេះពុំទាន់នាំមកនូវធាតុពិតនៃអំពើហិង្សាក្នុងគ្រួសារឱ្យមានសុក្រិតភាពនៅឡើយនៅកម្ពុជាទេ អាស្រ័យដោយមានការលាក់បាំងអំពីបញ្ហានេះដោយជនរងគ្រោះ[១៧] ។ ស្ត្រីត្រូវប្រឈមមុខនឹងភាពអាម៉ាស់ និងបាត់បង់កិត្តិយសក្នុងការស្វែងរកឱ្យគេជួយចំពោះបញ្ហាអំពើហិង្សាក្នុងគ្រួសារ និងត្រូវគេចាត់ទុកថា ជាអ្នកក្បត់នឹងគ្រួសារ ។ ជនរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារច្រើនតែរងគ្រោះក្នុងភាពស្ងប់ស្ងាត់ មិនសូវមានគេដឹងឮទេច្រើនតែលាក់លៀម ដើម្បីកុំឱ្យគ្រួសារជួបភាពអាម៉ាស់ ។ ជនល្មើសនៃអំពើហិង្សាក្នុងគ្រួសារបានផ្អែកលើភាពស្ងាត់ស្ងៀមនេះ ហើយដើម្បីបន្តប្រព្រឹត្តិរំលោភឥតឈប់ឈរ ។

## កង្វះការយល់ដឹង និងការអប់រំអំពីអំពើហិង្សាក្នុងគ្រួសារ

រាជរដ្ឋាភិបាលកម្ពុជាបានបរាជ័យក្នុងការអប់រំសង្គមទាំងមូលអំពីបញ្ហាអំពើហិង្សាក្នុងគ្រួសារនេះ ។ រហូតមកដល់ពេលនេះ សង្គមស៊ីវិលនៅតែមានតួនាទីយ៉ាងធំធេងក្នុងការអប់រំ និងតស៊ូមតិលើប្រធានបទនេះ[១៨] ។

ជនរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារច្រើនតែមានអារម្មណ៍ថា ពួកគេមិនដឹងទៅស្វែងរកជំនួយនៅទីណា ។ អង្គការមិនមែនរដ្ឋាភិបាល (NGO) គឺជាកន្លែងតែមួយគត់ ដែលជនរងគ្រោះច្រើនតែទៅរកឱ្យជួយ[១៩] ។ តាមពិតកិច្ចការអប់រំនេះវាជាការទទួលខុសត្រូវរបស់រាជរដ្ឋាភិបាលកម្ពុជា ហើយពុំមែនសង្គមស៊ីវិលទេ ដែលជាអ្នកត្រូវផ្តល់ជំនួយកិច្ចការពារ និងអប់រំជនរងគ្រោះអំពីអំពើហិង្សាក្នុងគ្រួសារ នេះ ។

---

16 ស្ថិតិ លីកាដូ ឆ្នាំ២០០០- ២០០៥ - ស្ថិតិ អាដហុក ឆ្នាំ២០០០-២០០៥ និងស្ថិតិ CWCC ឆ្នាំ១៩៩៧-២០០៥ ។

17 Op Cit 2, P.15.

18 ឧទាហរណ៍ : កម្មវិធី ឆ្នាំសហគមន៍ប្រឆាំងនឹងអំពើហិង្សាក្នុងគ្រួសារ : របាយការណ៍ មជ្ឈមណ្ឌលធនធានស្ត្រី (គំរោងអ្នកច្បាប់ការពារសិទ្ធិមនុស្សកម្ពុជា CDP) ទី ១ កញ្ញា ២០០៥ ឬកម្មវិធីវិទ្យុឃែមបូរស្ត្តីពីការយល់ដឹងពីអំពើហិង្សាក្នុងគ្រួសារ ឆ្នាំ២០០៥ ។

19 ព័ត៌មានផ្តល់ដោយអង្គការប្រឆាំងនឹងអំពើហិង្សាក្នុងគ្រួសារ ខែកញ្ញា ២០០៥ ។ អង្គការនេះបានផ្តល់សេវាពិគ្រោះយោបល់រហូតដល់ ៥៣១ នាក់ ពីឆ្នាំ១៩៩៦ ដល់ ២០០៥ ។

# ឧបសគ្គចម្បងៗ

## *ការអនុវត្តន៍ច្បាប់*

នគរបាលនិងមន្ត្រីនានាមានការស្ទាក់ស្ទើរក្នុងការជ្រៀតជ្រែកនូវអ្វីដែលគេយល់ថាជាបញ្ហា "ផ្ទៃក្នុងគ្រួសារ" និងច្រើនតែបដិសេធមិនធ្វើការស៊ើបអង្កេតនូវអ្វីដែលគេបានអះអាងថាជាអំពើហិង្សាក្នុងគ្រួសារ[២០] ដែលធ្វើឱ្យច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារទៅជាគ្មានប្រសិទ្ធិភាព ។

## *រដ្ឋាភិបាលគ្មានឆន្ទៈក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើហិង្សាក្នុងគ្រួសារ*

រាជរដ្ឋាភិបាលកម្ពុជាមិនទាន់ខិតខំប្រឹងប្រែងឱ្យអស់លទ្ធភាពនៅឡើយក្នុងការអប់រំ និងហ្វឹកហ្វឺននគរបាល មេធាវី ចៅក្រម និងសាធារណៈជនទូទៅដើម្បីលើកកំពស់ការយល់ដឹងអំពីភាពធ្ងន់ធ្ងរ នៃបញ្ហាហិង្សាក្នុងគ្រួសារនៅឡើយទេ ។ នៅមិនទាន់ច្បាស់នៅឡើយថា តើរដ្ឋាភិបាលយកចិត្តទុកដាក់ហ្មត់ចត់ក្នុងការប្រយុទ្ធប្រឆាំងនឹងបញ្ហាអំពើហិង្សាក្នុងគ្រួសារដែរឬទេ ឬគ្រាន់តែពិចារណាលើរបាយការណ៍ ដោយមិនធ្វើអ្វីសោះចំពោះប្រធានបទនេះ។

## *ភាពអន់ថយនៃវប្បធម៌*

សុភាសិតប្រពៃណី និងច្បាប់ទំនៀមទំលាប់កម្ពុជាច្រើនតែធ្វើឱ្យមានការលំបាកដល់ស្ត្រីក្នុងការនិយាយជំទាស់នឹងអំពើហិង្សាក្នុងគ្រួសារ និងស្វែងរកការជួយ[២១] ។ គេច្រើនតែព្រមានស្ត្រីមិនឱ្យយករឿងអំពើហិង្សាក្នុងគ្រួសារទៅនិយាយនៅក្រៅផ្ទះ ហើយសុភាសិតមួយចំនួនបានទូន្មានស្ត្រីឱ្យប្រយ័ត្នក្នុងការនាំរឿងយកទៅខាងក្រៅ។ "*កុំនាំភ្លើងក្រៅមកឯក្នុង ទុកឱ្យឆេះធំ*"[២២] ។ គេបានព្រមានស្ត្រីថា ការនាំយករឿងទៅខាងក្រៅនោះបណ្តាលឱ្យមានរឿងកាន់តែធំឡើង ។ "ប្រសិនបើអ្នកមិនប្រយ័ត្ននោះ អ្នកនឹងនាំភ្លើង ខាងក្នុងទៅបង្កាត់ឯខាងក្រៅ..."[២៣]

---

[20] របាយការណ៍ស្តីពីសិទ្ធិស្ត្រីកម្ពុជា ឆ្នាំ ២០០៤ : របាយការណ៍សង្ខេបស្តីពីស្ថានភាពស្ត្រីកម្ពុជា (លីកាដូ ខែកក្កដា ឆ្នាំ២០០៤) ទំព័រ ៨ ។
[21] Op Cit 4, P 15. Citing Luco
[22] ឯកសារដដែល ទំព័រ១២។ Citing Luco Fabenne។ នៅចន្លោះ ខ្លា និងគោ (ភ្នំពេញ: UNESCO 2000) ទំព័រ២២ Footnote 50។
[23] ឯកសារដដែល។

នៅកម្ពុជា ឋានានុក្រមបុរសមានភាពលើសលុប ហើយឋានានុក្រមនេះអាចឃើញច្បាស់នៅក្នុងគ្រួសារ និងក្នុងសង្គមទូទៅ ។ "បុរសត្រូវបានគេចាត់ទុកថា ជាអ្នកធ្វើការសម្រេចចិត្តចុងក្រោយនៅក្នុងគ្រួសារ" ហើយសមាជិកគ្រួសារផ្សេងទៀតត្រូវតែធ្វើតាមគោរព និងស្តាប់បង្គាប់"។[២៤]

ការប្រកាន់ខ្ជាប់នូវវប្បធម៌អន់ថយរបស់ស្ត្រីកម្ពុជា បានធ្វើឱ្យមានការលំបាក ជាពិសេសសំរាប់ផ្ទាល់ខ្លួនក្នុងការទទួលបានការជួយជ្រោមជ្រែងពេលត្រូវដោះស្រាយនូវអំពើហិង្សាក្នុងគ្រួសារ ។

## អនុសាសន៍

រាជរដ្ឋាភិបាលកម្ពុជាគួរអនុវត្តនូវអនុសាសន៍ដូចខាងក្រោមនេះ :

- ដោយបានអនុម័តច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះរដ្ឋាភិបាលត្រូវចាប់ផ្តើមជាបន្ទាន់រៀបចំធ្វើយុទ្ធនាការអប់រំ និងការយល់ដឹងនៅទូទាំងប្រទេសដោយផ្តោតលើនគរបាល មេធាវី ចៅក្រម និងជាពិសេសសាធារណៈជនទូទៅស្តីពីអំពើហិង្សាក្នុងគ្រួសារ ។ ការអប់រំនេះត្រូវផ្តោតការយកចិត្តទុកដាក់ជាពិសេសសង្កត់ធ្ងន់ទៅលើបុរសៗ និងប្រជាពលរដ្ឋដែលរស់នៅតាមជនបទ ។
- បើកវគ្គហ្វឹកហ្វឺនដល់នគរបាល មេធាវី និងតុលាការដើម្បីអោយមានការទទួលស្គាល់ និងប្រយុទ្ធ ប្រឆាំងនឹងអំពើហិង្សាក្នុងគ្រួសារនៅកម្ពុជា ។
- ធ្វើយុទ្ធនាការអប់រំ ជាពិសេសនៅតាមជនបទ ដើម្បីប្រឆាំងនឹងទស្សនៈចាស់ គំរិលដែលគិតថា ស្ត្រីទាបជាងបុរស ហើយដើម្បីឱ្យពួកគេបានដឹងអំពីសិទ្ធិរបស់ខ្លួនក្នុងបរិបទគ្រួសារ ។
- បង្កើនចំនួនមន្ត្រីអនុវត្តច្បាប់ជាស្ត្រីដែលមានការហ្វឹកហ្វឺន និងមន្ត្រីផ្នែកច្បាប់ ដើម្បីធ្វើការពាក់ព័ន្ធនឹងជនរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារ ។
- ផ្តល់សេវាពិគ្រោះយោបល់ និងស្តារឡើងវិញដល់ជនរងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារ ។

---

[24] ឯកសារដដែល Citing Derks Annuska, Khmer Women on The Move:។ បទពិសោធន៍ទេសន្តប្រវេសន៍ និងទីក្រុងនៅកម្ពុជា Amsterdam Dutch University Press, 2005 ទំព័រ ៦០ ។

# III. រំលោភសេពសន្ថវៈ

## ស្ថានភាព

រំលោភសេពសន្ថវៈគឺជាបទឧក្រិដ្ឋមួយដ៏សាហាវដែលត្រូវបានប្រព្រឹត្តិមកលើស្ត្រីកម្ពុជា ។ អំពើនេះក៏ជាអំពើមួយដែលមានការទទួលស្គាល់តិចតួចផងដែរអាស្រ័យដោយឥរិយាបទសង្គម និងវប្បធម៌កម្ពុជាចំពោះស្ត្រីនិងការរួមភេទ ។ ពុំមានស្ថិតិណាមួយបង្ហាញឱ្យបានច្បាស់លាស់ទេ អំពីចំនួនស្ត្រីដែលត្រូវបានរំលោភសេពសន្ថវៈជារៀងរាល់ឆ្នាំនៅកម្ពុជា ។ ប៉ុន្តែ ក្នុងប៉ុន្មានឆ្នាំថ្មីៗកន្លងទៅនេះ ការរាយការណ៍អំពីបទឧក្រិដ្ឋ ករណីរំលោភសេពសន្ថវៈមានការកើនឡើងយ៉ាងខ្លាំង[២៥] ។ ប៉ុន្មានឆ្នាំថ្មីៗកន្លងទៅករណីហិង្សានៃអំពើរំលោភសេពសន្ថវៈ[២៦] ការរំលោភជាពួក[២៧] និងបទឧក្រិដ្ឋរំលោភលើកុមារ[២៨] និងស្ត្រី ក្មេងៗ[២៩] ក៏ត្រូវបានរាយការណ៍ទៅអង្គការមួយចំនួនដែរ ។

ការកើនឡើងនូវរបាយការណ៍នេះប្រហែលជាផ្សារភ្ជាប់ទៅនឹងការយល់ដឹងអំពីសិទ្ធិស្ត្រី អាស្រ័យ ដោយមានកិច្ចខិតខំប្រឹងប្រែងយ៉ាងខ្លាំងដោយសង្គមស៊ីវិលដើម្បីតស៊ូមតិ និងអប់រំហើយក៏ដោយសារ មានការកើនឡើងនូវការរាយការណ៍តាមប្រព័ន្ធផ្សព្វផ្សាយអំពីករណីរំលោភនេះផងដែរ[៣០] ។

ករណីរំលោភសេពសន្ថវៈនេះមិនត្រូវបានលើកឡើងនៅក្នុងរបាយការណ៍របស់រដ្ឋទេ អាស្រ័យដោយមិនមានការទទួលស្គាល់ថា រំលោភជាបទឧក្រិដ្ឋធ្ងន់ធ្ងរដែលប៉ះពាល់ដល់ស្ត្រីកម្ពុជា ។

---

[25] ស្ថិតិលីកាដូពី ឆ្នាំ២០០០ -២០០៥ ស្ថិតិអាដហុកពីឆ្នាំ ២០០០ - ២០០៥ និងស្ថិតិ CWCC ពីឆ្នាំ ១៩៩៧ -២០០៥ ។

[26] របាយការណ៍ករណី លីកាដូ ខេត្តកំពត ខែឧសភា ២០០៣ (ចម្លើយ-សំណួរសំភាសន៍) ។

[27] របាយការណ៍ករណី ខេត្តកំពុងឆ្នាំង ខែឧសភា ឆ្នាំ២០០៤ ទំព័រ ៦៥ នៃសេចក្តីបកប្រែ) ។

[28] របាយការណ៍ CWCC ។ ខេត្តកណ្តាល ខែមករា ឆ្នាំ២០០៥ (ទំព័រ ៤៩ នៃសេចក្តីបកប្រែ) ។

[29] របាយការណ៍ករណី អាដហុក ខែមិថុនា ឆ្នាំ២០០៣ (ទំព័រ ៧ អាដហុក CEDAW ។
រំលោភ និងបៀតបៀនកេរខ្មាស់

[30] រំលោភ និងបៀតបៀនកេរខ្មាស់ (របាយការណ៍លីកាដូ ខែមិនា ឆ្នាំ២០០៤ ) ទំព័រ ៥ ។

## ករណីរំលោភសេពសន្ថវៈដែលរាយការណ៍មកលីកាដូ




*តួលេខឆ្នាំ២០០៥ ចាប់ពីខែមករា ដល់ កក្កដា ប៉ុណ្ណោះ*

## នីតិកម្ម

អំពើរំលោភសេពសន្ថវៈគឺជាបទឧក្រិដ្ឋតាមច្បាប់ព្រហ្មទណ្ឌអន្តរកាល[៣១] និងក្រោមច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ[៣២] ។

## *និយមន័យនៃពាក្យរំលោភសេពសន្ថវៈ*

និយមន័យនៃពាក្យរំលោភសេពសន្ថវៈគឺ *"គ្រប់អំពើបញ្ចូលអង្គជាតិ ដោយឃោរឃៅ ដោយបង្ខំ ឬដោយមិនដឹងខ្លួនជាមុន"*[៣៣] ។

ការប្រព្រឹត្តិអំពើរំលោភសេពសន្ថវៈ ឬប៉ុនប៉ងរំលោភត្រូវចាត់ទុកជាបទឧក្រិដ្ឋដូចគ្នា តាមច្បាប់ព្រហ្មទណ្ឌកម្ពុជា។[៣៤]

## គោលនយោបាយ

ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រីមានគោលបំណងដើម្បីលើកស្ទួយស្ថានភាព តួនាទី និងសង្គមកិច្ចរបស់ស្ត្រីកម្ពុជាក្នុងគោលបំណងដើម្បីកាត់បន្ថយ និងលុបបំបាត់រាល់ទំរង់នៃការរើសអើង និងហិង្សាចំពោះស្ត្រីភេទ ។ ប៉ុន្តែទោះជាមានបែបនេះក្តីក៏នៅមិនទាន់ ឃើញមានគោលនយោបាយរដ្ឋាភិបាលជាក់លាក់ណាមួយស្តីអំពីការរំលោភសេពសន្ថវៈនៅកម្ពុជានៅឡើយដែរ ។

---

[31] ច្បាប់ព្រហ្មទណ្ឌអន្តរកាល មាត្រា ៣៣។

[32] ច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ មាត្រា ៥។

[33] ច្បាប់ព្រហ្មទណ្ឌអន្តរកាល មាត្រា ៣៣ និង ច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ មាត្រា ៥ ។

[34] ច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ មាត្រា ៥ ។

## ករណីរំលោភសេពសន្ថវៈដែលមិនរាយការណ៍

"ករណីដែលបានរាយការណ៍អាចជាផ្នែកមួយដ៏តូចនៃករណីរំលោភផ្លូវភេទពិតប្រាកដ ដែលប្រព្រឹត្តិឡើងពិតៗនៅកម្ពុជា ។ គ្មានអង្គការណាអាចប៉ាន់ប្រមាណដែលអាចជឿជាក់បានពីចំនួនករណីរំលោភសេពសន្ថវៈដែលត្រូវបិទបាំងមិនរាយការណ៍ជារៀងរាល់ថ្ងៃបានឡើយ[៣៥] ។

ចាប់ពីឆ្នាំ១៩៩៧ ‑២០០៥ មានករណីរំលោភសេពសន្ថវៈជាងមួយពាន់ករណីត្រូវបានរាយការណ៍មកអង្គការនានាដែលធ្វើការស៊ើបអង្កេត[៣៦] ។ ទោះជាយ៉ាងនេះក្តីតួលេខនេះក៏នៅតែជាការស្មានទាបជាងទំហំពិតនៃបទល្មើសរំលោភសេពសន្ថវៈដែលប្រព្រឹត្តិនៅក្នុងសង្គមកម្ពុជា ។ មានកត្តាជាច្រើនដែលអាចរួចចំណែកធ្វើឱ្យជនរងគ្រោះបដិសេធមិនរាយការណ៍អំពីករណីរំលោភ និងស្វែងរកបណ្តឹងតាមផ្លូវច្បាប់នេះ[៣៧] :

- មិនទុកចិត្តប្រព័ន្ធយុត្តិធម៌ (ជនរងគ្រោះប្រហែលជាខ្លាចមានអំពើពុករលួយនៅក្នុងប្រព័ន្ធតុលាការ) ។
- ការចំណាយក្នុងការស្វែងរកឱ្យមានការផ្តន្ទាទោស (ពុំមានតម្លៃស្របច្បាប់ ដែលត្រូវបង់ឱ្យតុលាការទេក្នុងការប្តឹងករណីព្រហ្មទណ្ឌ ប៉ុន្តែ ជាក់ស្តែងការចំណាយជាសម្ងាត់ពិតជាមាននៅគ្រប់ជាន់ថ្នាក់ទាំងអស់អាស្រ័យដោយមន្ត្រីពុករលួយ) ។
- ជនរងគ្រោះអាចខ្លាចការសងសឹកពីជនល្មើស (ជាពិសេសពេលដែលជនល្មើសជាជនមានតួនាទីអំណាចលើជនរងគ្រោះ) ។
- ជំនឿវប្បធម៌ និងសង្គម (ជូនកាលជនរងគ្រោះអាចជឿថាជាកំហុសរបស់ខ្លួនដែលបណ្តាលឱ្យមានអំពើរំលោភនេះកើតឡើង) ។
- "ការសងជម្ងឺចិត្ត" ក្រៅផ្លូវការរវាងជនល្មើស និងជនរងគ្រោះ (ករណីជាច្រើនត្រូវបានដោះស្រាយខាងក្រៅផ្លូវតុលាការ) ។
- ការបាត់បង់ព្រហ្មចារី (ជនរងគ្រោះអាចប្រឈមនឹងភាពអាម៉ាស់ប្រសិនបើនាងបាត់បង់ព្រហ្មចារីដោយសារអំពើរំលោភសេពសន្ថវៈនេះ) ។ ការបាត់បង់ព្រហ្មចារីនេះអាចចាត់ទុកជាការសំខាន់ជាងការដាក់ទោសជនល្មើសទៅទៀត ។

---

35 OP cit 30, P.6.

36 ស្ថិតិលីកាដូពី ឆ្នាំ ២០០០ ‑២០០៥ ស្ថិតិអាដហុកពីឆ្នាំ ២០០០ ‑ ២០០៥ និងស្ថិតិ CWCC ពីឆ្នាំ ១៩៩ ‑២០០៥ ។

37 Op Cit 30, P. 6.

## ឥរិយាបទសង្គម និងវប្បធម៌កម្ពុជា

អំពើរំលោភសេពសន្ថវៈនៅកម្ពុជា ត្រូវតែពិនិត្យមើលក្នុងបរិបទឥរិយាបទវប្បធម៌ និងសង្គមកម្ពុជាចំពោះការរួមភេទរវាងបុរស និងស្ត្រី ។ នៅក្នុងសង្គមកម្ពុជា បុរសទទួលបានតម្លៃខ្ពស់ជាងស្ត្រី[៣៨] ។ ពំនោលដ៏មានប្រជាប្រិយមួយនៅកម្ពុជាបានចែងថា "បុរសគឺជាមាសទឹកដប់ ហើយស្ត្រីគឺជាសំពត់ស"។ ពំនោល នេះបង្ហាញនូវបទដ្ឋានត្រួតគ្នានៅកម្ពុជា ដែលបុរសអាចរួមភេទបានតាមចិត្តហើយមិនចេះខូច ខាតឡើយដូចជាមាសទឹកដប់ ដែលនៅតែភ្លឺដដែលពេលលាងសំអាតរួចហើយ ។ ប៉ុន្តែចំពោះ ស្ត្រីវិញ ប្រសិនបើបាត់បង់ព្រហ្មចារី ហើយនោះប្រៀបដូចជាសំពត់សដែលប្រឡាក់ភក់ ហើយមិនអាចដុសលាង ឱ្យជ្រះបានវិញទេ[៣៩] ។ ពំនោលនោះបានបង្ហាញយ៉ាងច្បាស់ថា ស្ត្រីកម្ពុជាត្រូវតែប្រុងប្រយ័ត្ន ដើម្បីធានានូវភាពបរិសុទ្ធរបស់ខ្លួន និងគោរពតាមច្បាប់ប្រពៃណីឱ្យបានខ្ជាប់ខ្ជួន..នៅក្នុងសង្គមកម្ពុជា ស្ត្រីដែលបាត់បង់ព្រហ្មចារីយ (ទោះបីជានាងត្រូវរំលោភសេពសន្ថវៈក៏ដោយ) មុននឹងនាងរៀបការនោះ ជាការនាំមកនូវក្តីអាម៉ាស់ដល់កិតិយសគ្រួសាររបស់នាង"។[៤០]

ការរួមភេទមុនរៀបអាពាហ៍ពិពាហ៍គឺជាប្រការមិនអាចទទួលយកបានទេចំពោះស្ត្រីកម្ពុជា ដូច្នេះ គេសង្ឃឹមថា ស្ត្រីត្រូវតែរក្សាព្រហ្មចារីឱ្យបានរហូតដល់ពេលរៀបការ បើមិនដូច្នេះទេ គេយល់ថាស្ត្រីនោះមិនសមនឹងរៀបការទេ ទោះបីជាស្ត្រីនោះត្រូវរំលោភសេពសន្ថវៈក៏ដោយ។[៤១]

ជនរងគ្រោះដោយអំពើរំលោភសេពសន្ថវៈជាច្រើនបានលាក់ទុកនូវបញ្ហាយ៉ាងស្ងៀមស្ងាត់ ជាមួយនឹងភាពអាម៉ាស់ ឬភ័យខ្លាច ឬជនរងគ្រោះទាំងនេះអាចបន្ទោសខ្លួនឯងចំពោះបញ្ហាដែលកើតឡើង ។ ចំពោះបញ្ហានេះវាក៏ជាការលំបាកផងដែរ សំរាប់មនុស្សទូទៅក្នុងការយល់នូវប្រភេទនៃអំពើរំលោភផ្សេងៗ ។ ឧទាហរណ៍ ប្រជាពលរដ្ឋអាចរាយការណ៍នូវករណីរំលោភសេពសន្ថវៈលើកុមារ[៤២] ប៉ុន្តែ

---

38 រំលោភ និងបៀតបៀនកេរខ្មាស់ : របាយការណ៍ទឧក្រិដ្ឋនៅក្នុងសហគមន៍ (Diane O'connel, របាយការណ៍ពិសេសលីកាដូ ខែកុម្ភៈ ២០០១ ) ទំព័រ ១០ ។ របាយការណ៍អង្គការមិនមែនរដ្ឋាភិបាលកម្ពុជាស្តីពីការអនុវត្តន៍នៃវេទិការក្រុងប៉េកាំងដើម្បីសកម្មភាព (រៀបចំដោយក្រុមការងារស្ត្រី៥ ប៉េកាំង អំពីយែនឌ័រ និងបណ្តាញអភិវឌ្ឍន៍ និងក្រុមការងារស្ត្រីនៃវេទិការអង្គការមិនមែនរដ្ឋាភិបាល ខែកុម្ភៈ ឆ្នាំ២០០០ ) ទំព័រ ២១

39 ឯកសារដដែល ទំព័រ ១០ គ្រូពេទ្យសិទ្ធិមនុស្ស ១៩៩៦. អាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារនៅកម្ពុជា (Personal Narrative: ទស្សនៈចិត្តសាស្ត្រ Boston ១៩៩៧ ) ។ ឯកសារដដែល

40 ឯកសារដដែល ទំព័រ ១២. ប្រពន្ធល្អ : ការពិភាក្សាជាមួយស្ត្រីរៀបការអំពីជីវិត សុខភាព អាពាហ៍ពិពាហ៍ និងការរួមភេទ (CARE International Cambodia, Phnom Penh, 2001) ។

41 Op cit 38, P. 10 . កុមារនិងយុវជនដែលត្រូវរំលោភ និងជួញដូរផ្លូវភេទនៅកម្ពុជា ការវាយតម្លៃនូវតំរូវការសុខភាពរបស់ពួកគេ និងសេវាដែលមានស្រាប់ក្នុងខេត្តមួយចំនួនតាមបែប Qualitative ។ គណៈកម្មាធិការ សង្គម និងសេដ្ឋកិច្ចនៃអង្គការសហប្រជាជាតិសំរាប់អាស៊ី និងប៉ាស៊ីហ្វិច New York 2000។

42 ស្ថិតិលីកាដូពី ឆ្នាំ ២០០០ .២០០៥ ស្ថិតិអាដហុកពីឆ្នាំ ២០០០.២០០៥ និងស្ថិតិCWCC ពីឆ្នាំ ១៩៩៧.២០០៥ ។ ពន្យល់ថា

រំលោភសេពសន្ថវៈក្នុងអាពាហ៍ពិពាហ៍ ឬអ្នកដែលមានទំនាក់ទំនងស្នេហាប្រហែលជាមិនត្រូវបានគេចាត់ទុកថា ជាអំពើរំលោភសេពសន្ថវៈឡើយ ដោយស្ត្រីតែងតែសុខចិត្តបំពេញបំណងរបស់ដៃគូរខ្លួនជានិច្ច ។ មានការគាំទ្រយ៉ាងខ្លាំង ចំពោះទណ្ឌកម្មជាប់ពន្ធនាគារដល់ជនល្មើសដែលបានប្រព្រឹត្តិអំពើរំលោភសេពសន្ថវៈ ប៉ុន្តែពុំសូវមានការគាំទ្រដល់ការដាក់ពន្ធនាគារទេពេលដែលជនល្មើសជាសង្សា ឬគូរស្នេហ៍របស់ស្ត្រី ។[៤៣]

អំពើរំលោភលើស្ត្រីរកស៊ីផ្លូវភេទក៏មិនត្រូវបានទទួលស្គាល់ជាទូលំទូលាយដែរ ។ ការសិក្សាមួយបានបង្ហាញឱ្យឃើញថាមនុស្សវ័យក្មេងនៅភ្នំពេញមួយចំនួនធំមិនជឿថា ការរំលោភជាពួកលើស្ត្រីរកស៊ីផ្លូវភេទ ដែលគេហៅថា "បូក" នោះជាបទឧក្រិដ្ឋឡើយ ។ ការសិក្សានោះបានរកឃើញថា មានតែមនុស្សប្រុស និងស្រី ១៣ ភាគរយតែប៉ុណ្ណោះដែល "ទទួលស្គាល់ថា ទំនាក់ទំនងផ្លូវភេទដោយបង្ខំរវាងស្ត្រីរកស៊ីផ្លូវភេទម្នាក់ និងបុរសជាច្រើនជាអំពើរំលោភ ឬជាអំពើខុសពីព្រោះស្ត្រីរកស៊ីផ្លូវភេទពុំអនុញ្ញាតឱ្យធ្វើដូច្នេះ"។[៤៤] អ្នកដែលបានរស់រានមានជីវិតពីអំពើរំលោភច្រើនតែជួបប្រទះនូវឥរិយាបទរើសអើងពីសង្គមដែលចាត់ទុកពួកគេថាជា "ស្រីខូច" ។ ការឈប់រាប់អានពីសំណាក់សង្គម និងភាពអាមាស់របស់គ្រួសារជាលទ្ធផល ដែលកើតចេញពីការបាត់បង់ព្រហ្មចារីពេលដែលត្រូវរំលោភជាកត្តាដ៏ធំ ដែលនាំឱ្យជនរងគ្រោះមួយចំនួនមានអារម្មណ៍ថា មុខជំនាញតែមួយគត់ដែលសមនឹងពួកគេនោះគឺពេស្យាចារ ។ ឪពុកម្តាយខ្លះថែមទាំងបានលើក ទឹកចិត្តកូនស្រីរបស់ខ្លួនឱ្យចូលទៅក្នុងមុខរបរពេស្យាចារក៏មាន ប្រសិនបើកូននោះអស់ព្រហ្មចារីហើយ ។ ក្នុងករណីខ្លះទៀត ជនរងគ្រោះត្រូវបានបង្ខំឱ្យរៀបការជាមួយនឹងជនដែលរំលោភនាង ដើម្បីជួយស្រោចស្រង់កិត្តិយសរបស់គ្រួសារ។[៤៥]

## ឧបសគ្គចម្បងៗ

### *ការខ្វះចន្លោះនៃមាត្រាដែលចែងអំពីរំលោភសេពសន្ថវៈនៅក្នុងច្បាប់បច្ចុប្បន្ន*

មានការខ្វះចន្លោះមួយចំនួននៅក្នុងច្បាប់ស្តីពីរំលោភសេពសន្ថវៈបច្ចុប្បន្ន ។ ឧទាហរណ៍ច្បាប់មិនបានពន្យល់និយមន័យនៃពាក្យយល់ព្រមចំពោះសកម្មភាពរួមភេទឱ្យបានច្បាស់លាស់ទេ ដូច្នេះមន្ត្រីផ្នែកច្បាប់អាចជួបការលំបាកក្នុងការកំណត់ថាតើក្នុងការរួមភេទនោះ ពិតជាមានការយល់ព្រមដែរឬអត់នោះ។

---

[43] Op cit 4, P 9: ពន្យល់ថា នៅកម្ពុជា ពាក្យថា "សង្សា" គឺត្រូវបានប្រើពិពណ៌នាទំនាក់ទំនងដែលកើតឡើងមុនពេលរៀបការ ហើយពាក្យ "គូរស្នេហ៍ " ត្រូវបានប្រើដើម្បីបង្ហាញនូវទំនាក់ទំនងជាច្រើនដែលមានក្រៅពីអាពាហ៍ពិពាហ៍ (ឧទាហរណ៍ ដូចជាប្រើសំរាប់ការរៀបការជាមួយ "ប្រពន្ធទី២") ដែលពុំមែនជាស្នេហ៍តែម្តង ដូចជា ស្នេហ៍ជាមួយស្ត្រីរកលុយឡើយ ។

[44] Op cit 30, P. 23 Citing Paupers and Pricelings: ឥរិយាបទយុវជនចំពោះក្រុមក្មេងពាល ហិង្សា រំលោភ គ្រឿងញៀន និងចោរកម្ម (GAD, 2003) ទំព័រ ៨ ។

[45] Op Cit 38, P. 1.

ច្បាប់បច្ចុប្បន្នក៏ខ្វះនូវមាត្រា ដែលចែងឱ្យបានច្បាស់ផងដែរចំពោះការរំលោភក្នុងអាពាហ៍ពិពាហ៍ និងក្នុងគ្រួសារ ។ ប៉ុន្តែច្បាប់ ដែលទើបតែអនុម័តថ្មីៗកន្លងទៅនេះ គឺច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះបានចាត់ទុកអំពើរំលោភដោយហិង្សានៅក្នុងរង្វង់គ្រួសារជាអំពើ "ខុសច្បាប់"។[៤៦] អំពើរំលោភក្នុងអាពាហ៍ពិពាហ៍ក៏ជាអំពើខុសច្បាប់ផងដែរ ។

## *ការបកស្រាយច្បាប់ខុសដោយតុលាការ ព្រះរាជអាជ្ញា និងមធាវីការពារក្តី*

ចៅក្រមនានាត្រូវតែអនុវត្តការបកស្រាយច្បាប់ឱ្យបានហ្មត់ចត់នៅកម្ពុជា ។ "ចៅក្រមមិនត្រូវប្រើនីតិវិធី ឬការបកស្រាយច្បាប់ណាមួយដែលមិនត្រូវបានផ្តល់ឱ្យដោយច្បាប់ឡើយ ។ ការប្រើប្រាស់បែបណាមួយក្នុងការសម្រេចចិត្តជាលទ្ធផលអាចត្រូវបានមោឃភាពនូវសេចក្តីសម្រេចចិត្តនោះដោយតុលាការ កំពូល"។[៤៧] ប៉ុន្តែការបកស្រាយខុសនៅក្នុងមាត្រាស្តីពីរំលោភសេពសន្ថវៈបានកើតឡើងក្នុងករណីជាច្រើននៅតុលាការកម្ពុជា ។

ការបកស្រាយច្បាប់ខុសអាចកើតឡើងពេលដែលតុលាការប្រើប្រាស់ពាក្យថា ការរំលោភបំពាន និងបាត់បង់ព្រហ្មចារីដើម្បីកំណត់ថា តើមានការរំលោភសេពសន្ថវៈឬក៏គ្មាននោះ ។ តាមពិតចៅក្រមបានបញ្ជាក់ថា គ្មានអំពើរំលោភសេពសន្ថវៈទេ ប្រសិនបើ "គ្រាន់តែប៉ះពីខាងក្រៅប៉ុណ្ណោះ"។[៤៨] ឬថារំលោភ មិនដល់ទីជម្រៅ ហើយពុំមានការបាត់បង់ព្រហ្មចារីទេនោះ។[៤៩] ប៉ុន្តែមាត្រាស្តីពីរំលោភសេពសន្ថវៈបានចែង យ៉ាងច្បាស់ណាស់ដោយនិយាយថា ជនណាម្នាក់ដែលប៉ុនប៉ងប្រព្រឹត្តិអំពើរំលោភសេពសន្ថវៈនឹងត្រូវមានទោសដូចបទល្មើសរំលោភដែរ ។[៥០] ដូច្នេះហើយ ចៅក្រមមិនគួរប្រើប្រាស់ការសាកល្បងទាំងនេះ ដើម្បីកំណត់ថាតើជនរងគ្រោះត្រូវរំលោភ ឬអត់ទេ ។

កង្វះភស្តុតាងលើរូបរាងកាយ និងកោសល្យវិច្ច័យក៏អាចនាំឱ្យតុលាការពិចារណាថាមានការយល់ព្រមក្នុងការរួមភេទនោះដែរ ។ នៅក្នុងករណីរំលោភសេពសន្ថវៈជាច្រើន លិខិតកោសល្យវិច្ច័យបានបញ្ជាក់ថា ជនរងគ្រោះត្រូវបានរំលោភ ដូច្នេះតុលាការត្រូវប្រើប្រាស់លិខិតកោសល្យវិច្ច័យនេះ ដើម្បីកាត់ទោសជនល្មើស ។ តុលាការចាត់ទុកលិខិតកោសល្យវិច្ច័យជាវិធីសាស្ត្របឋមក្នុងការកំណត់ថាជនរង

46 ច្បាប់ស្តីពីការទប់ស្កត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ- មាត្រា ៧ ។

47 Op Cit 30, P. 19. សៀវភៅក្បួនតុលាការ (គំរោងជំនួយយុត្តិធម៌ព្រហ្មទណ្ឌកម្ពុជា ខែកក្កដា ឆ្នាំ១៩៩៩) ទំព័រ ១១៩ ។

48 Op Cit 30, P 19, Citing Bill Bainbridge & Lon Nara " ជនល្មើសមួយសើរីត្រឡប់មកតុលាការវិញក្រោមបទចោទប៉ុនប៉ងរំលោភសេពសន្ថវៈ ។ ភ្នំពេញប៉ុស្តិ ២៤ ឧសភា ដល់ ៦ មិថុនា ២០០២ ។ ការគ្រប់គ្រងព្រហ្មចារីធ្វើឱ្យជនល្មើសរួចពីអន្ទាក់ ។

49 Op Cit 30, P. 19 Citing Stephen O'Connell & Lon Nara, ការគ្រប់គ្រងព្រហ្មចារីធ្វើឱ្យជនល្មើសរួចពីអន្ទាក់ ភ្នំពេញប៉ុស្តិ ៥-១៨ មករា ២០០១ ។

50 ច្បាប់ព្រហ្មទណ្ឌអន្តរកាល មាត្រា ៣៣ និងច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃព្រហ្មទណ្ឌ -មាត្រា ៥ ។

គ្រោះពុំយល់ព្រម ។ [៥១] ប្រសិនបើគ្មានភស្តុតាងអំពើរំលោភលើរូបរាងកាយ និងគ្មានលិខិតកោសល្យវិច្ច័យដើម្បីបញ្ជាក់ការពិតនេះទេ ពេលនោះចៅក្រមអាចប្រកាសថា ការរួមភេទនោះប្រាកដជាមានការព្រមព្រៀងគ្នា ហើយនោះពុំមែនជាអំពើរំលោភសេពសន្ថវៈទេ។[៥២]

## *និទណ្ឌភាព*

វប្បធម៌និទ្ទណ្ឌភាព បច្ចុប្បន្ននេះនៅតែមានកើតឡើងចំពោះជនល្មើសដែលប្រព្រឹត្តិអំពើរំលោភសេពសន្ថវៈនៅកម្ពុជា ។ ជនល្មើសរំលោភជាច្រើនអាចជឿជាក់ថាពួកគេស្ថិតនៅពីលើច្បាប់ ហើយប្រសិនបើពួកគេត្រូវចាប់បាននោះទណ្ឌកម្មរបស់គេតែមួយគត់គឺការចំណាយលុយ ។[៥៣] ប៉ុន្តែ និទ្ទណ្ឌភាពទំនងជាកើតមានច្រើនពេលដែលជនល្មើសជាអ្នកធូធារ ឬមានអំណាចដូចជានគរបាលយោធា ឬមន្ត្រីរាជការជាដើម ។[៥៤] ជនរងគ្រោះដោយអំពើរំលោភសេពសន្ថវៈអាចមានអារម្មណ៍ថា ជនល្មើសដែលរំលោភខ្លួននឹងមិនត្រូវបានផ្តន្ទាទោសទេ ហើយនេះអាចធ្វើឱ្យពួកគេរុញរាក្នុងការរាយការណ៍នូវបទល្មើសរំលោភ ឬរុញរាក្នុងការបន្តប្តឹងតាមផ្លូវច្បាប់ ។

## *អំពើពុករលួយ*

អំពើពុករលួយបានបង្ហាញភស្តុតាងយ៉ាងច្បាស់នៅក្នុងប្រព័ន្ធតុលាការកម្ពុជា ។ ឧទាហរណ៍ ជនល្មើសអាចចំណាយលុយឱ្យនគរបាលដើម្បីកុំឱ្យចាប់ខ្លួន សូកលុយតុលាការដើម្បីឱ្យមានការបន្ថយការចោទប្រកាន់ ឬលើកលែងការចោទប្រកាន់ ឬទទួលការផ្តន្ទាទោសទាប ។[៥៥] នៅគ្រប់ដំណាក់កាលទាំងអស់នៃដំណើរការបណ្តឹង ជនរងគ្រោះដោយអំពើរំលោភសេពសន្ថវៈត្រូវប្រឈមមុខនឹងការចំណាយសំរាប់សកម្មភាពតុលាការ ដូចជា ចំណាយលើការធ្វើដំណើរទៅជួបតុលាការ ឬចំណាយលើការសូកប៉ាន់ក្រឡាបញ្ជីតុលាការដើម្បីឱ្យបញ្ជូនបណ្តឹងបទរំលោភនោះទៅលើទៀត ។ តាមមាត្រា ៣៨ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាលការគិតថ្លៃ និងការប្រព្រឹត្តិបែបនេះគឺជាអំពើខុសច្បាប់ ។

## *ការសងសំណងរដ្ឋប្បវេណីខុសច្បាប់*

ឧបសគ្គដ៏ធំបំផុតចំពោះការផ្តន្ទាទោសជនល្មើសគឺការអនុវត្តន៍ខុសច្បាប់ ដោយការសងជម្ងឺចិត្ត ។ ការសងជម្ងឺចិត្តនេះគឺជាការដោះស្រាយក្រៅប្រព័ន្ធតុលាការដ៏មានប្រសិទ្ធិភាពរវាងជនរងគ្រោះ និងជន

---

[51] Op Cit 30, P. 13.
[52] ឯកសារដដែល ។
[53] Op Cit 38, P 10, ការសង្កេតនេះគឺផ្អែកទៅលើការសម្ភសន៍បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល ។
[54] Op Cit 38, P 51.
[55] Op Cit 30, P 11.

ល្មើស ។ ក្នុងករណីនេះ ជនល្មើសបង់លុយឱ្យជនរងគ្រោះដើម្បីកុំឱ្យជនរងគ្រោះប្តឹងទៅតុលាការ ។ ជនល្មើសមានលទ្ធភាពចំណាយលុយដើម្បីគេចផុតពីការផ្តន្ទាទោស ។

ការអនុវត្តន៍បែបនេះត្រូវបានចាក់ ឫសយ៉ាងជ្រៅនៅកម្ពុជាជាច្រើនឆ្នាំមកហើយ ។ ជនរងគ្រោះ អាចមិនរាយការណ៍ករណីនេះទៅនគរបាល ប៉ុន្តែបែរជាទាមទារសំណងជម្ងឺចិត្តពីជនល្មើទៅវិញ ។ នៅ ក្នុងករណីខ្លះទៀត នគរបាលអាចជំរុញឱ្យជនរងគ្រោះដោះស្រាយជាមួយនឹងជនល្មើសដូច្នេះ នគរបាល អាចទទួលបាននូវចំណែកណាមួយដោយការជួយសម្របសម្រួលក្នុងការសងជម្ងឺចិត្តនេះ ។ ជារឿយៗ គ្រួសាររបស់ជនរងគ្រោះមានអារម្មណ៍ថា ពួកគេគ្មានជំរើសពីព្រោះពួកគេស្ថិតនៅក្នុងស្ថានភាពលំបាក ដូចជា ក្រីក្រ និងគ្មានបក្សពួក ហើយពួកគេអាចត្រូវបានគំរាមកំហែង ឬបំភិតបំភ័យដោយអាជ្ញាធរ ឬគ្រួសារជនជាប់ ចោទ។[៥៦]

តាមច្បាប់កម្ពុជា ជនរងគ្រោះដោយអំពើរំលោភសេពសន្ថវៈត្រូវមានសិទ្ធិធ្វើបណ្តឹងពីរ គឺបណ្តឹងព្រហ្មទណ្ឌ និងបណ្តឹងរដ្ឋប្បវេណី ។ បណ្តឹងរដ្ឋប្បវេណីនេះអាចនាំឱ្យមានការសងជម្ងឺចិត្តដោយជនល្មើស ។ ប៉ុន្តែការសងជម្ងឺចិត្តជាលទ្ធផលដែលកើតចេញពីបណ្តឹងរដ្ឋប្បវេណីនេះពុំមែនជាការបញ្ចប់សិទ្ធិរបស់ជនរងគ្រោះក្នុងការប្តឹងជនល្មើសនូវបណ្តឹងព្រហ្មទណ្ឌឡើយ ។ ប៉ុន្តែដោយហេតុថាមានការអនុវត្តន៍ការសងជម្ងឺចិត្តខុសច្បាប់មានការកើនឡើងនៅកម្ពុជា ហើយនៅក្នុងករណីជាច្រើនត្រូវបានផ្តួចផ្តើមដោយនគរបាល និងអាជ្ញាធរផ្សេងៗទៀតក៏មាន[៥៧] ជនរងគ្រោះអាចមិនយល់ថា ការដោះស្រាយបែបនេះជាការរារាំងរដ្ឋមិនអាចផ្តន្ទាទោសជនល្មើសបានឡើយ ។

## អនុសាសន៍

រាជរដ្ឋាភិបាលកម្ពុជាគួរអនុវត្តអនុសាសន៍ដូចខាងក្រោមនេះ :

- ចាប់ផ្តើមធ្វើយុទ្ធនាការតស៊ូមតិជាប្រចាំដើម្បីអប់រំពលរដ្ឋកម្ពុជា (ដោយផ្តោតទៅលើស្ត្រី) អំពីប្រធានបទរំលោភសេពសន្ថវៈ ។ ឧទាហរណ៍ តើអំពើរំលោភសេពសន្ថវៈជាអ្វី? តើត្រូវធ្វើដូច ម្តេចប្រសិនបើនរណាម្នាក់ត្រូវគេរំលោភ?

[56] Op Cit 38, P 51.
[57] Op Cit 38, P. 36.

- អប់រំមន្ត្រីច្បាប់ និងតុលាការអំពីការបកស្រាយច្បាប់រំលោភឱ្យបានត្រឹមត្រូវ ។ ផ្តន្ទាទោសមន្ត្រីណាដែលបកស្រាយច្បាប់ខុស និងរំលោភច្បាប់ រួមទាំងមន្ត្រីណាដែលចូលរួម ឬសម្រប សម្រួលក្នុងការដោះស្រាយសងជម្ងឺចិត្តខុសច្បាប់ ។
- អនុម័តច្បាប់រំលោភ ដោយកំណត់និយមន័យនៃពាក្យ "យល់ព្រម" ក៏ដូចជាធាតុផ្សំនៃបទល្មើស (ឧទាហរណ៍ការរំលោភបំពាន ឬការប៉ុនប៉ងត្រូវចាត់ទុកជាបទល្មើសរំលោភ) ។
- ផ្តល់ការពិគ្រោះយោបល់ និងមណ្ឌលស្តារលទ្ធភាពដល់ជនរងគ្រោះដោយអំពើរំលោភ ។

# IV. អំពើជួញដូរស្ត្រី

ចាប់តាំងពីដើមទសវត្ស ១៩៩០ មក ចំនួនស្ត្រីកម្ពុជាដែលត្រូវបានគេជួញដូរមានការកើនឡើងយ៉ាងខ្ពស់ ។[៥៨] ភាគច្រើននៃការជួញដូរគឺក្នុងគោលបំណងធ្វើអាជីវកម្មផ្លូវភេទ ។ ការកើនឡើងនៃការជួញដូរនេះអាចទាក់ទងទៅនឹង "ការផ្លាស់ប្តូរសង្គម និងសេដ្ឋកិច្ចដែលពាក់ព័ន្ធនឹងអន្តរកាលពីប្រព័ន្ធសង្គមនិយមបិទជិតទៅជាប្រព័ន្ធសហគ្រាសមូលធន"។[៥៩] វត្តមានអ៊ុនតាក់(១៩៩១-១៩៩៣) ក្រោយពីសង្គ្រាមស៊ីវិលរាប់សតវត្សក៏បានកើតមានតំរូវការយ៉ាងធំនូវឧស្សាហកម្មផ្លូវភេទ ហើយត្រូវបានជឿជាក់ថាជាការរួមចំណែកឱ្យមានការរីកដុះដាលនៃមុខរបរជួញដូរមនុស្សនេះផងដែរ ។[៦០]

ក្នុងឆ្នាំ ២០០៥ កម្ពុជាត្រូវបានទទួលស្គាល់ជាផ្លូវការថា ជាប្រទេសដែលមានការជួញដូរស្ត្រីដ៏អាក្រក់បំផុត[៦១] ហើយត្រូវបានចាត់ចូលជាប្រទេសដែលមានលំដាប់ថ្នាក់លេខ ៣ ដោយសហរដ្ឋអាមេរិក ពីព្រោះរាជរដ្ឋាភិបាលកម្ពុជាពុំបានធ្វើឱ្យមានការរីកចំរើនក្នុងការទប់ស្កាត់អំពើជួញដូរមនុស្ស និងផ្តល់កិច្ច ការពារដល់ជនរងគ្រោះដោយអំពើជួញដូរឡើយ ។

ដូចគ្នានឹងគ្រប់ទំរង់នៃហិង្សាលើស្ត្រីភេទដែរ គេមិនអាចដឹងបានទេពីចំនួនជាក់លាក់នៃស្ត្រីកម្ពុជា ដែលត្រូវបានគេជួញដូរនោះ ។ ប៉ុន្តែរបាយការណ៍ថ្មីៗជាច្រើនបានបង្ហាញឱ្យដឹងថា ចំនួនស្ត្រីកាន់តែច្រើនឡើងត្រូវបានគេជួញដូរទៅប្រទេសម៉ាឡេស៊ី[៦២] សិង្ហបូរី[៦៣] ថៃឡង់ដ៍[៦៤] និងវៀតណាម[៦៥] ក្នុងគោលបំណងផ្សេង ដូចជា ការកេងប្រវ័ញ្ចផ្លូវភេទ អ្នកបំរើការងារផ្ទះដោយបង្ខំ និងជាកម្មកររោងចក្រ។

របាយការណ៍រដ្ឋបានធ្វើការកត់សំគាល់ថា "ការជួញដូរស្ត្រីគឺជាទំរង់ដ៏អាក្រក់បំផុតនៃអំពើហិង្សា

---

58 គំរោងស្រាវជ្រាវ និងសកម្មភាពអំពីការជួញដូរស្ត្រីនៅក្នុងតំបន់ទន្លេមេគង្គ (កម្ពុជា និងវៀតណាម) សម្ព័ន្ធភាពពិភពលោកប្រឆាំងនឹងការជួញដូរស្ត្រី របាយការណ៍ឆ្នាំ ២០០១ ទំព័រ ២ ។

59 ឯកសារដដែល ទំព័រ ១៤ ។ របាយការណ៍ CWDA ឆ្នាំ ១៩៩៩ ។ ទំព័រ ៧ ។

60 ឯកសារដដែល ទំព័រ ១៤ ។

61 បាយការណ៍បន្ថែមថ្មីរបស់ UNIFEM ផ្ញើមក ឃែមបូវ ខែកញ្ញា ឆ្នាំ២០០៥ ។

62 ការជួញដូរស្ត្រី និងកុមារកម្ពុជា: របាយការណ៍ ការស្វែងរកការពិតនៅម៉ាឡេស៊ី (CWCC សីហា ២០០៥)

63 ឯកសារដដែល ។

64 ការវិលត្រឡប់ និងការធ្វើសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្សពីកម្ពុជា ប្រទេសថៃ ០១ កក្កដា ២០០៤ - ៣០ មិនា ២០០៥ និងការធ្វើមាតុភូមិនិវត្តជនរងគ្រោះជាតិវៀតណាមពីកម្ពុជាទៅវៀតណាម ពីថ្ងៃទី១៥ ឧសភា ១៩៩៩-៣០ មិនា ២០០៥ (ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនិតិ សម្បទា- របាយការណ៍ ២០០៥ )។

65 ឯកសារដដែល ។

លើស្ត្រីភេទ”[៦៦] ហើយផ្តល់នូវព័ត៌មានអំពីការចាត់វិធានការដើម្បីកំណត់អត្តសញ្ញាណទប់ស្កាត់ និងប្រយុទ្ធ ប្រឆាំងនឹងការជួញដូរស្ត្រី និងកុមារីទាំងនៅក្នុងនិងក្រៅកម្ពុជា[៦៧] ។ ប៉ុន្តែ មកដល់បច្ចុប្បន្ននេះពុំទាន់ ឃើញមានការវាយតម្លៃណាមួយលើប្រសិទ្ធិភាពនៃវិធានការ និងកម្មវិធីនីមួយៗក្នុងការកាត់បន្ថយអំពើ ជួញដូរស្ត្រីឡើយ ។

## ករណីជួញដូរមនុស្សដែលបានរាយការណ៍មកលីកាដូ




*តួលេខឆ្នាំ ២០០៥ ចាប់ពីខែ មករា ដល់ ខែកក្កដា ប៉ុណ្ណោះ*

## នីតិកម្ម

អំពើជួញដូរមនុស្សខុសនឹងច្បាប់ស្តីពីការបង្ក្រាបអំពើចាប់ជំរិត ជួញដូរមនុស្ស អាជីវកម្មមនុស្ស[៦៨] និងច្បាប់រដ្ឋធម្មនុញ្ញ ។[៦៩]

## *និយមន័យនៃពាក្យជួញដូរមនុស្ស*

នៅក្នុងច្បាប់ជាតិ ពុំមានច្បាប់ណាមួយមានចែងនិយមន័យច្បាស់លាស់អំពីការជួញដូរមនុស្សទេ ។ ប៉ុន្តែ គេបានគេទទួលយកយ៉ាងទូលំទូលាយថា រូបភាពលេចធ្លោនៃអំពើជួញដូរមនុស្សគឺតាមរយៈការ បង្ខិតបង្ខំ ឬការបោកបញ្ឆោតក្នុងគោលបំណងធ្វើអាជីវកម្ម ។[៧០]

---

66 របាយការណ៍បឋម របាយការណ៍ទី ២ និងរបាយការណ៍ដំណាក់កាលទី៣ ដែលរៀបចំឡើងដោយរាជរដ្ឋាភិបាលកម្ពុជាផ្ញើជូនទៅគណៈកម្មាធិការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនារីភេទ កថាខណ្ឌ ១៥៦ ទំព័រ ២៩ ។

67 ឯកសារដដែល កថាខណ្ឌ ១៨៥ ទំព័រ ៣២ -៣៣ ។

68 ច្បាប់ស្តីពីការបង្ក្រាបអំពើចាប់ជំរិត ជួញដូរ និងអាជីវកម្មលើមនុស្ស មាត្រា ២ ។

69 ច្បាប់រដ្ឋធម្មនុញ្ញមាត្រា ៤៦ ។

70 ការវិភាគយែនឌ័រ គំរូនៃការជួញដូរមនុស្សចូល និងឆ្លងកាត់ខេត្តកោះកុង (ការឧបត្ថម្ភផ្នែកច្បាប់សំរាប់កុមារ និងស្ត្រី ខែ មករា ឆ្នាំ ២០០៥ ទំព័រ ១៣ ។ Citing Huntington D.; 2002.

*សេចក្តីព្រាងច្បាប់ប្រឆាំងនឹងអំពើជួញដូរមនុស្ស*

បច្ចុប្បន្ននេះ រដ្ឋសភាជាតិកំពុងពិនិត្យសេចក្តីព្រាង *ច្បាប់ស្តីពីអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទឡើងវិញ* ។ សេចក្តីព្រាងច្បាប់ប្រឆាំងនឹងអំពើជួញដូរមនុស្សនេះនឹងផ្តល់ឱ្យមន្ត្រីអនុវត្តច្បាប់ និងតុលាការនូវអំណាចខ្លាំងជាងមុនក្នុងការឃាត់ខ្លួន និងផ្តន្ទាទោសជនល្មើសជួញដូរមនុស្ស និងផ្តល់កិច្ចការពារដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ។

## គោលនយោបាយ

ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី មានបំណងលើកកំពស់ឋានៈតួនាទី និងសុខុមាលភាពសង្គមរបស់ស្ត្រីកម្ពុជាដើម្បីកាត់បន្ថយ និងលុបបំបាត់រាល់ទម្រង់នៃការរើសអើង និងហិង្សាចំពោះនារីភេទ ។ លើសពីនេះទៀត ក្រសួងកិច្ចការនារីក៏បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងមួយ ដើម្បីប្រយុទ្ធប្រឆាំងរាល់ទម្រង់នៃអំពើជួញដូរស្ត្រី និងកុមារនៅកម្ពុជាសំរាប់រយៈពេល៣ ឆ្នាំពី (២០០០-២០០៣) ជាមួយនឹងរដ្ឋាភិបាលហ្វាំងឡង់[៧១] ។ កម្មវិធីនេះសំរាប់មន្ត្រីនៅតាមតំបន់ព្រំដែនអនុវត្តឆ្លើយតបទៅនឹងអំពើជួញដូរស្ត្រីនិងកុមារ ។

អាជ្ញាធរក្រុងភ្នំពេញក៏បានបង្កើតនូវគណៈកម្មាធិការចំរុះមួយ ដើម្បីអនុវត្តសេចក្តីណែនាំអំពីគោលនយោបាយទប់ស្កាត់អាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ ។ គោលបំណងរបស់គណៈកម្មាធិការនេះ គឺស្វែងរក និងផ្តន្ទាទោសជនល្មើសជួញដូរមនុស្ស ។

## ផលប៉ះពាល់នៃសង្គមក្រោយជម្លោះ

បញ្ហាអំពើជួញដូរស្ត្រីកម្ពុជាអាចទាក់ទងនឹងប្រវត្តិសាស្ត្រថ្មីៗរបស់កម្ពុជា ។ ទសវត្សនៃសង្គ្រាមស៊ីវិល ភាពរីករវើផ្នែកសេដ្ឋកិច្ច និងនយោបាយបានធ្វើឱ្យមានការប៉ះពាល់យ៉ាងខ្លាំងលើជីវិត ស្ថានភាព និងតួនាទីរបស់បុរស និងស្ត្រីនៅក្នុងគ្រួសារក៏ដូចជាក្នុងសង្គមទាំងមូល ។[៧២] ការបាត់បង់អាយុជីវិតមនុស្សដ៏ច្រើនមហិមាក្នុងសម័យខ្មែរក្រហមបានធ្វើឱ្យបាត់បង់នូវមូលដ្ឋានសម្ភារៈវប្បធម៌ និងអារម្មណ៍ទាំងក្នុងគ្រួសារ និងសហគមន៍ទាំងមូល ។[៧៣] បច្ចុប្បន្ននេះនៅសេសសល់ប្រព័ន្ធគាំទ្រតិចជាងប្រព័ន្ធ

---

[71] កិច្ចព្រមព្រៀងនេះត្រូវបានចុះហត្ថលេខានៅខែមិនា ឆ្នាំ ២០០០។

[72] Op Cit 58, P. 14 Citing, បញ្ហាយែនឌ័រក្នុងសម័យអន្តរកាលកម្ពុជា (របាយការណ៍មជ្ឈមណ្ឌលសិក្សាដើម្បីអភិវឌ្ឍន៍ - v.ii, no. 3, វិច្ឆិកា ១៩៩៦) ។

[73] Op Cit 58 Citting, Sean and Barr, 1998, P.16.

គាំទ្រដែលធ្លាប់មាននៅក្នុងសាច់សារលោហិត និងក្នុងសហគមន៍ដើម្បីជួយគ្រួសារក្រីក្រនានា ឬអ្នកទាំងឡាយដែលជួបប្រទះបញ្ហា ។ នេះអាចចាត់ទុកថាជាកត្តារួមផ្សំមួយដែលនាំឱ្យមានការកើនឡើងនៃអំពើជួញដូរស្ត្រីនៅក្នុងប្រទេស។[៧៤]

## ភាពក្រីក្រ និងទេសន្តប្រវេសន៍ ( ចំណាកស្រុក)

កត្តាជាមូលដ្ឋានពីរដែលបណ្តាលឱ្យមានអំពើជួញដូរស្ត្រីគឺភាពក្រីក្រ និងការធ្វើចំណាកស្រុក ។ ស្ត្រីក្នុងគ្រួសារក្រីក្រ និងខ្វះការអប់រំបានក្លាយទៅជាជនងាយរងគ្រោះដោយអំពើអាជីវកម្ម និងជួញដូរមនុស្សក្នុងខណៈពេលធ្វើចំណាកស្រុកដោយពួកគេត្រូវធ្វើដំណើរទៅតំបន់ផ្សេងៗ ដូចជា ភ្នំពេញ និងឆ្លងដែនទៅប្រទេសថៃ[៧៥] ដើម្បីស្វែងរកការងារ ។ ជាពិសេសស្ត្រីរស់នៅតាមតំបន់ព្រំដែន ដូចជា ខេត្តកោះកុង បន្ទាយមានជ័យ និងស្វាយរៀងជាដើមគឺជាស្ត្រីដែលងាយធ្លាក់ចូលក្នុងអំពើជួញដូរមនុស្សខ្លាំងណាស់ ។ ភាគច្រើន ច្រើនតែចាញ់បោកគេដោយសារការនាំទៅរកការងារធ្វើតាមរយៈជនខិលខូចដែលតែងតែសន្យាជួយជូនឱ្យដល់ទីដៅជាថ្នូនឹងប្រាក់ឈ្នួល ។ ដំណើរនេះត្រូវបានគេស្គាល់ថា "ជាការជ្រើសរើស" ។

ក្នុងកំឡុងពេលធ្វើចំណាកស្រុកជារឿយៗ ស្ត្រីច្រើនតែពឹងផ្អែកទាំងស្រុងទៅលើជនខិលខូច ។ ក្រោយពីបានមកដល់ទីក្រុង ឬប្រទេសថ្មីមួយដែលស្ត្រីទាំងនោះមិនចេះនិយាយភាសា គ្មានប្រព័ន្ធជួយគាំទ្រ ឬជំនួយត្រង់ចំណុចនេះហើយដែលស្ត្រីងាយរងនូវឧបាយកលបោកបញ្ឆោត[៧៦] និងអំពើជួញដូរមនុស្ស ។ នៅពេលនោះចំណងបំណុលក៏អាចកើតមានឡើងដែរ គេបានប្រាប់ស្ត្រីទាំងនោះថា ពួកនាងបានជំពាក់បំណុលអ្នកដែលជួយនាំនាងធ្វើដំណើរមក ហើយនាងត្រូវតែសងបំណុលនេះ ដោយត្រូវធ្វើការជាពេស្យាចារ ឬការងារក្នុងអ្វីមួយ ។[៧៧] ជួនកាលបំណុលក៏ចេះតែកើតឡើងពេល ដែលពុំមានការកាត់បន្ថយបំណុលឱ្យបានសមរម្យ ហើយជនរងគ្រោះអាចជំពាក់បំណុលច្រើនជាងការចំណាយក្នុងការធ្វើដំណើរទៅទៀត (បញ្ហានេះអាចកើតឡើងទីណាដែលជនខិលខូចមានបំណងចង់ឱ្យជនរងគ្រោះជំពាក់បំណុលកាន់តែយូរតាមដែលអាចធ្វើទៅបាន)។[៧៨]

---

[74] ឯកសារដដែល ។
[75] Op Cit 70, P36.
[76] ឯកសារដដែល ។
[77] Op Cit 58, P.6.
[78] ឯកសារដដែល ។

## អំពើពេស្យាចារ

ស្ត្រីជាច្រើនត្រូវបានជួញដូរចូល និងចេញពីកម្ពុជាដើម្បីធ្វើការក្នុងឧស្សាហកម្មផ្លូវភេទ ប៉ុន្តែចំនួនស្ត្រីដ៏ច្រើនបំផុតត្រូវបានជួញដូរក្នុងប្រទេសកម្ពុជាខ្លួនឯង[៧៩] ការស្រាវជ្រាវបានបង្ហាញឱ្យឃើញថា ៦៥.៤៥% នៃស្ត្រីរកស៊ីផ្លូវភេទត្រូវបានរងការបង្ខិតបង្ខំឱ្យចូលក្នុងអំពើពេស្យាចារនេះ ៥២.៩% ត្រូវបានបោកបញ្ឆោត ដោយការសន្យារកការងារឱ្យធ្វើចំណែក ១១.០៤% ត្រូវបានលក់ដោយសមាជិកក្នុងគ្រួសារ និង ០.៥៨% ទៀតបានរងអំពើរំលោភសេពសន្ថវៈ ។[៨០] ក្នុងករណីស្ត្រីដែលត្រូវជួញដូរក្នុងគោលបំណងផ្លូវភេទភាគរយនៃពួកស្ត្រីដែលអះអាងថា ពួកគេត្រូវបោកដោយការសន្យារកការងារឱ្យបានប្រសើជាងមុននោះ មានការកើនឡើង ។[៨១] ជនរងគ្រោះដោយការជួញដូរក្រៅកម្ពុជា ដែលត្រូវបង្ខំឱ្យធ្លាក់ចូលក្នុងអំពើពេស្យាចារក៏អាចត្រូវប្រឈមមុខនឹងការចាប់ខ្លួន និងការចោទប្រកាន់ពីបទឧក្រិដ្ឋចំពោះការជាប់ពាក់ព័ន្ធនៅក្នុងរបរផ្លូវភេទ[៨២] ក៏ដូចជាការរងគ្រោះពីបញ្ហាសុខភាព និងជម្ងឺផ្សេងៗ ដូចជាអេដស៍ជាដើម ។[៨៣]

របាយការណ៍ស្តីអំពី "យែនឌ័រ ការជួញដូរមនុស្ស និងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌកម្ពុជា" របស់សហប្រតិបត្តិការតំបន់អាស៊ីដើម្បីទប់ស្កាត់ការជួញដូរមនុស្ស បានធ្វើការកត់សំគាល់ថា បញ្ហាមួយដែលប្រឈមមុខនឹងអំពើជួញដូរមនុស្ស គឺការបង្ក្រាបអាជីវកម្មផ្លូវភេទគ្រប់រូបភាពវាប្រសើរជាងការបង្ក្រាបតែទៅលើអ្វីដែលគេចាត់ទុកទម្រង់អាក្រក់បំផុត គឺពេស្យាចារកុមារ និងពេស្យាចារបង្ខិតបង្ខំ ពេស្យាចារកុមារ និងពេស្យាចារដោយបង្ខំ ភាគច្រើនបានមានការពាក់ព័ន្ធជាមួយនឹងការជួញដូរ ។ ប្រការនេះបានជំរុញឧស្សាហកម្មភេទធ្លាក់ជ្រៅទៅៗ និងងាកទៅរកធ្វើឱ្យស្ថានភាពកាន់តែអាក្រក់ ជាងធ្វើឱ្យស្ថានការណ៍កាន់តែប្រសើរ ។ ម្យ៉ាងទៀត ដោយមិនបានបែងចែកឱ្យដាច់ពីគ្នារវាងការងារភេទដោយបង្ខំ និងមិនបង្ខំប្រព័ន្ធនេះបានលើកទឹកចិត្តម្ចាស់បនក្នុងការធ្វើអាជីវកម្ម ដោយប្រើកំលាំងពលកម្មបង្ខំ និងចំណាយតិចជាង ។[៨៤]

---

79 Op Cit 7, P.18.
80 របាយាករណ៍ប្រចាំឆ្នាំ ខែ មករា -ធ្នូ ២០០២ (CWCC, ២០០២ ) ទំព័រ ៧ ។
81 Op Cit 7, P. 19.
82 យែនឌ័រ ការជួញដូរមនុស្ស និងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌកម្ពុជា (សហប្រតិបត្តិការតំបន់អាស៊ី ដើម្បីទប់ស្កាត់ការជួញដូរមនុស្ស ខែធ្នូ ២០០៣ ) ទំព័រ ១៤ ។
83 Op Cit 70, P 54.
84 ទំព័រ ១៤ ។

## ឧបសគ្គផ្សេងៗ

### *ការរំលោភច្បាប់អន្តោប្រវេសន៍*

មានការចង្អុលបង្ហាញថា "ស្ត្រី និងកុមារីដែលត្រូវបានគេជួញដូរត្រូវបានគេប្រព្រឹត្តិមកលើពួកគាត់ដូចជា ជនឧក្រិដ្ឋដែលបានរំលោភច្បាប់អន្តោប្រវេសន៍ ហើយមិនត្រូវបានគេប្រព្រឹត្តិមកលើពួកគាត់ដូចជាជនរងគ្រោះ ដែលបាត់បង់សិទ្ធិសេរីភាពនោះទេ"។[៨៥] ជនរងគ្រោះដោយអំពើជួញដូរច្រើនតែត្រូវផ្តន្ទាទោសក្រោម ការចោទប្រកាន់ពីបទអន្តោប្រវេសនខុសច្បាប់ ។[៨៦] មកដល់ពេលនេះ រាជរដ្ឋាភិបាល កម្ពុជាពុំទាន់បានព្រាងច្បាប់ណាមួយដើម្បីការពារជនរងគ្រោះពីសំណាក់ការផ្តន្ទាទោសក្រោមការចោទប្រកាន់ពីបទអន្តោប្រវេសន៍ខុសច្បាប់ឡើយ ។ របាយការណ៍ពីបណ្តាប្រទេសដែលមានស្ត្រីត្រូវបានចោទប្រកាន់ពីបទអន្តោប្រវេសន៍ខុសច្បាប់[៨៧]បានបង្ហាញថា អនុសារណៈយោគយល់គ្នារវាងរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលនៃប្រទេសទទួលអាចមានប្រយោជន៍ដល់ជនរងគ្រោះដោយអំពើជួញដូរនៅក្នុងតំបន់ ។

ឧទាហរណ៍ តាមបេសកកម្មទៅប្រទេសម៉ាឡេស៊ីដើម្បីស្វែងរកការពិតរបស់មជ្ឈមណ្ឌលកម្ពុជាដើម្បីស្ត្រីមានវិបត្តិ (CWCC)[៨៨] បានរកឃើញថា ស្ត្រីកម្ពុជាដែលត្រូវបានជួញដូរ និងត្រូវមានទោសពីបទ អន្តោប្រវេសន៍ខុសច្បាប់ជាធម្មតាត្រូវបានឃុំនៅក្នុងមជ្ឈមណ្ឌល ។ ជារឿយៗជនរងគ្រោះពុំមានអ្នកបកប្រែ ឬមេធាវីទេ និងវាអាស្រ័យទៅលើ "ការអាណិតអាសូរ និងមេត្តាករុណាពីសំណាក់ឆ្មាំ" ។[៨៩] បេសកកម្ម ក៏បានរកឃើញផងដែរថា ជនរងគ្រោះទាំងឡាយដែលបញ្ចប់ការបំរើទោសរបស់គេក៏ ត្រូវបានរក្សាទុកក្នុងជុំរំឃុំឃាំងផងដែរ ដោយគ្មានអាជ្ញាធរណាមកជួយនាំពួកគេត្រឡប់មកកម្ពុជាវិញ ឡើយ ។[៩០]

បេសកកម្មស្វែងរកការពិតរបស់មជ្ឈមណ្ឌលកម្ពុជាដើម្បីស្ត្រីមានវិបត្តិបានធ្វើការកត់សំគាល់ផងដែរថាអាចមានលទ្ធភាពដែលស្ត្រីរងគ្រោះដោយអំពើជួញដូរទាំងនោះក្លាយទៅជនរងគ្រោះ ឬត្រូវជួញដូរម្តងទៀត ។[៩១] បញ្ហានេះតែងតែកើតឡើងនៅពេលដែលសមាជិកនៃបណ្តាញជួញដូរទៅជួបស្ត្រីទាំង

---

85 បញ្ជីបញ្ហា និងសំណួរចំពោះការពិចារណារបាយការណ៍កម្ពុជា (គណៈកម្មាធិការលុបបំបាត់អំពើរើងអើងប្រឆាំងស្ត្រី ក្រុមការងារមនុស្សសម័យប្រជុំសំរាប់សម័យប្រជុំលើកទី៣៤ ពីថ្ងៃទី១៦ មករា ដល់ ៣ កុម្ភៈ ២០០៦) កថាខណ្ឌ ១៣ ទំព័រ ៦ ។

86 Op Cit 82, P. 14.

87 Op Cit 62, P. 27.

88 Op Cit 62, P. 28.

89 Op Cit 62, P. 14.

90 ទំព័រ ២៧ ។

91 ទំព័រ ២៨ ។ គំរោង

នោះក្នុងមណ្ឌលឃុំឃាំង ហើយ "ស្រោចស្រង់ពួកគេ" ។ បន្ទាប់មកជនរងគ្រោះត្រូវគេបង្ខំឱ្យធ្វើការនៅក្នុងវិស័យពេស្យាចារ ឬលក់ឱ្យអ្នកទិញផ្សេងទៀត។

### *កង្វះខាតច្បាប់ការពារ*

ច្បាប់បច្ចុប្បន្នមិនគ្រប់គ្រាន់ក្នុងការការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស ការដាក់ទណ្ឌកម្មដល់ជនល្មើស និងការទប់ស្កាត់អំពើជួញដូរមនុស្ស ។ សេចក្តីព្រាងច្បាប់ស្តីពីអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទនៅមិនទាន់អនុម័តនៅឡើយ ។ វាជាការចាំបាច់ដែលរាជរដ្ឋាភិបាលកម្ពុជា និងធន្ទះនយោបាយត្រូវតែជំនះភាពខ្វះចន្លោះនៅក្នុងច្បាប់ប្រឆាំងអំពើជួញដូរបច្ចុប្បន្ន ។

### *កង្វះការអនុវត្តន៍ច្បាប់ និងនិទណ្ឌភាព*

មានបញ្ហាជាច្រើននៅក្នុងច្បាប់ប្រឆាំងការជួញដូរដែលគ្មានប្រសិទ្ធិភាព ។ ចៅក្រមខេត្តមួយចំនួនបានត្អូញត្អែរអំពីកង្វះការណែនាំឱ្យបានច្បាស់លាស់ក្នុងការផ្តន្ទាទោសអ្នកជួញដូរមនុស្ស ហើយចៅក្រមទាំងនោះបានប្រើប្រាស់ចំណុចខ្វះខាតនេះសំរាប់ជាការដោះសារពេលមានឧបសគ្គនានានៅក្នុងការអនុវត្តន៍ច្បាប់ ។[៩២] ទោះជាយ៉ាងនេះក្តី បញ្ហាធ្ងន់ធ្ងរជាងនេះទៅទៀតចំពោះការ ផ្តន្ទាទោសជនល្មើសគឺចៅក្រមមានជាប់ទាក់ទងនឹងបញ្ហាមួយចំនួនដូចជា អំពើពុករលួយនិទ្ទណ្ឌភាពបានរួមគំនិតក្នុងការអនុវត្តន៍ច្បាប់ធូររលង់ រួមមទាំងអារម្មណ៍បំរើបំរួលរបស់មន្ត្រីអនុវត្តច្បាប់ទៅលើផលអាក្រក់នៃអំពើជួញដូរមនុស្ស។[៩៣]

នៅកម្ពុជា ច្បាប់មិនត្រូវបានអនុវត្តឱ្យបានតឹងរឹងទេ ហើយការដាក់ទណ្ឌកម្មនៅខ្សោយនៅឡើយ ។ គេបានដឹងថាអាជ្ញាធរស៊ីសំណូកជាពិសេសសំណូកជារូបិយបណ្ណបរទេស ហើយអាជ្ញាធរខ្លះទៀតជាដៃ គូម្ចាស់ផ្ទះបន និងអាជីវកម្មពេស្យាចារ ។[៩៤] ជួនកាលករណីមួយចំនួនត្រូវបានដោះស្រាយតាមការអន្តរាគមន៍ពីសំណាក់នគរបាល ហើយខណៈដែលជនល្មើសបង់សំណងរដ្ឋប្បវេណីទៅជនរងគ្រោះ[៩៥] នគរបាលក៏បានទទួលបានទ្វរកម្រៃខ្លះពីការដោះស្រាយខុសច្បាប់នេះ ។ ជនល្មើសមួយចំនួនក៏សង្ឃឹមថានឹងបានការជួយជ្រោមជ្រែងពីសំណាក់មន្ត្រីនគរបាលអន្តោប្រវេសន៍ ដែលប្រចាំការនៅទីប្រជុំជនសំខាន់ៗមានការជួញដូរមនុស្សតាមព្រំដែនកម្ពុជា ដូចជាប៉ោយប៉ែតជាដើម (នៅជាប់ព្រំដែនថៃ)។[៩៦]

---

[92] គំរោងស្រាវជ្រាវ និងសកម្មភាពជួញដូរស្ត្រី និងកុមារនៅតំបន់មេគង្គ-ករណីកម្ពុជា (ភ្នាក់ងារអភិវឌ្ឍន៍ស្ត្រីកម្ពុជា) របាយការណ៍បឋម ១៩៩៨ ។

[93] Op Cit 82, P. 32.

[94] ឯកសារដដែល ។

[95] Op Cit 70, P. 77.

[96] Op Cit 7, P. 19.

ជនល្មើសតិចតួចណាស់ដែលធ្លាប់ត្រូវបានផ្តន្ទាទោស និងកាត់ឱ្យជាប់ទោស ជាពិសេស ករណីជួញដូរមនុស្សបានជាគំរូអាក្រក់មួយ ខណៈដែលនិទណ្ឌភាពបានក្លាយជាវិធានដែលគ្រាន់តែធ្វើយ៉ាងណាឱ្យការកាត់ឱ្យជាប់ទោសនេះមានភាពប្លែកពីធម្មតាបន្តិចបន្តួច ។[៩៧]

## *ខ្វះវិធានការមាតុភូមិនិវត្តិសមាហរណកម្ម និងស្តារឡើងវិញ*

ខណៈដែលមានការប៉ុនប៉ងក្នុងការធ្វើមាតុភូមិនិវត្តិជនរងគ្រោះដោយអំពើជួញដូរពីប្រទេសមួយ ចំនួនដូចជា ថៃឡង់ដ៍[៩៨] និងវៀតណាម[៩៩] កិច្ចខិតខំប្រឹងប្រែងដោយរាជរដ្ឋាភិបាលកម្ពុជាដើម្បីជួយ ជនរងគ្រោះដោយអំពើជួញដូរទាំងនោះនៅតែមិនទាន់គ្រប់គ្រាន់នៅឡើយ ។ កម្ពុជាក៏នៅខ្វះវិធានការ ធ្វើសមាហរណកម្ម និងស្តារលទ្ធភាពឱ្យបានទូលំទូលាយចំពោះជនរងគ្រោះដែរ ។ ដើម្បីជួយស្រ្តីទាំងនេះធ្វើសមាហរណកមឱ្យបានជោគជ័យត្រឡប់ទៅលំនៅដ្ឋានរបស់ពួកគេវិញ រាជរដ្ឋាភិបាលកម្ពុជាត្រូវតែមានកិច្ចខិតខំប្រឹងប្រែងរួមមួយសំរាប់រៀបចំ និងអនុវត្តកម្មវិធីជាក់លាក់បានជាជំនួយដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ។

## អនុសាសន៍

រាជរដ្ឋាភិបាលកម្ពុជាគួរអនុវត្តអនុសាសន៍ខាងក្រោមជាបន្ទាន់:

- អនុម័តសេចក្តីព្រាងច្បាប់ស្តីពីអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ និងអនុវត្តមាត្រាទាំង ឡាយឱ្យបានសមរម្យ ។
- វាយតម្លៃនូវប្រសិទ្ធិភាពនៃវិធានការ និងកម្មវិធីរបស់រដ្ឋាភិបាលក្នុងការកាត់បន្ថយអំពើជួញដូរស្រ្តី ។
- អប់រំមន្រ្តីច្បាប់ និងតុលាការក្នុងការអនុវត្តន៍ច្បាប់ប្រឆាំងនឹងអំពើជួញដូរបច្ចុប្បន្ន ។
- បើកវគ្គហ្វឹកហ្វឺន និងអប់រំដល់នគរបាល និងមន្រ្តីព្រំដែនដែលធ្វើការជិតស្និទ្ធិនឹងអំពើជួញដូរមនុស្ស និងមជ្ឈមណ្ឌលអាជីវកម្មភេទ ។
- បង្កើនចំនួនមន្រ្តីអនុវត្តច្បាប់ជាស្រ្តីដែលមានការហ្វឹកហ្វឺន និងចំនួនមន្រ្តីអនុវត្តច្បាប់ដែលដែលធ្វើការជាមួយជនរងគ្រោះដោយអំពើជួញដូរ និងអាជីវកម្មផ្លូវភេទ ។

---

[97] ឯកសារដដែល ។ ស្ថានភាពសិទ្ធិមនុស្ស (សមាគមន៍សិទ្ធិមនុស្ស និងអភិវឌ្ឍន៍កម្ពុជា របាយការណ៍ ខែ មករា ២០០៤) ទំព័រ ៤០ ។

[98] របាយការណ៍រដ្ឋកថាខ័ណ ១៨៦ ទំព័រ ៤០ ។

[99] Op Cit 64.

- បង្កើនកិច្ចខិតខំប្រឹងប្រែងដើម្បីធ្វើមាតុភូមិនិវត្តិជនរងគ្រោះដោយអំពើជួញដូរ និងជួយអង្គការ មិនមែនរដ្ឋាភិបាលទាំងឡាយដែលចូលរួមយ៉ាងសកម្មក្នុងកិច្ចប្រឹងប្រែង ដើម្បីធ្វើមាតុភូមិនិវត្តិ ។
- ផ្តល់សេវាប្រឹក្សាយោបល់ ការស្តារលទ្ធភាព និងការធ្វើសមាហរណកម្មជូនជនរងគ្រោះដោយអំពើជួញដូរមនុស្ស ។

# V. សេចក្តីសន្និដ្ឋាន

របាយការណ៍បានស្រាវជ្រាវរកឃើញបញ្ហាហិង្សាលើស្ត្រីនៅកម្ពុជា ដែលពាក់ព័ន្ធនឹងអំពើហិង្សាក្នុងគ្រួសាររំលោភសេពសន្ថវៈ និងអំពើជួញដូរមនុស្ស ។ គោលបំណងនៃរបាយការណ៍គឺដើម្បីបញ្ជាក់នូវស្ថានភាពបច្ចុប្បន្ននៃទំរង់ហិង្សានីមួយៗ និងដើម្បីស្រាវជ្រាវរកឧបសគ្គនានា ដែលតំរូវឱ្យមានការព្យាយាម ដើម្បីប្រយុទ្ធប្រឆាំងនឹងអំពើហិង្សាបែបនេះ ។ នៅពីក្រោយឧបសគ្គទាំងនេះ គឺការឆ្លើយតបមិនបានពេញលេញរបស់រាជរដ្ឋាភិបាលកម្ពុជា និងឆន្ទៈនយោបាយក្នុងការដោះស្រាយបញ្ហានានា និងការចាប់ផ្តើមធ្វើការកែទម្រង់ ។ ការកែទម្រង់ផ្នែកនីតិកម្មការ ផ្នែកអប់រំ និងការកែទម្រង់លើប្រយោជន៍នានា ដែលពាក់ព័ន្ធដល់សង្គមវប្បធម៌ ទាំងអស់នេះធ្វើឱ្យមានអំពើហិង្សាយូរអង្វែង ។

## នីតិកម្ម

អនុវត្តច្បាប់ដែលត្រូវបានអនុម័តថ្មី គឺច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ គឺជាអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា ។ ដូចគ្នានេះដែរ សេចក្តីព្រាងច្បាប់ស្តីពីអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទក៏ត្រូវតែអនុម័តផងដែរ ។ ទាំងនេះគឺជាជំហានសំខាន់ៗក្នុងការអនុវត្តន៍គោលការណ៍នៃអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទំរង់នៃការរើសអើងចំពោះស្ត្រីភេទ និងអប់រំសាធារណៈជនថា ហិង្សាគឺជាបទឧក្រិដ្ឋ ។ ប៉ុន្តែច្បាប់ទាំងឡាយអាចនឹងមានអំណាច និងប្រសិទ្ធិភាពបានលុះត្រាតែមនុស្សអនុវត្តច្បាប់ទាំងនោះ ។ ទាំងនគរបាល និងតុលាការត្រូវទទួលស្គាល់យ៉ាងពេញលេញនូវសុពលភាពនៃច្បាប់ទាំងនេះ ទោះបីជាឥរិយាបទសង្គមដ៏យូរលង់អាចខុសពីអ្វីដែលសរសេរនៅក្នុងច្បាប់នេះក៏ដោយ ។

លើសពីនេះទៀត រាជរដ្ឋាភិបាលកម្ពុជាត្រូវតែប្រើយន្តការសំរាប់វាយតម្លៃនូវប្រសិទ្ធិភាពនៃច្បាប់ទាំងនេះ ។ រាជរដ្ឋាភិបាលកម្ពុជានឹងអាចដឹងថា តើច្បាប់ទាំងនេះបានបំពេញនូវបំណងរបស់ខ្លួន និងសក្តានុពល ឬយ៉ាងណានោះ គឺអាស្រ័យដោយមានការត្រួតពិនិត្យការអនុវត្តន៍ច្បាប់ទាំងនោះ ។

## ឥរិយាបទសង្គម និងការអប់រំ

ការអប់រំគឺជាគន្លឹះមួយក្នុងការធ្វើឱ្យមានឥរិយាបទសង្គម ដែលបណ្តាលឱ្យមានហិង្សាលើស្ត្រីភេទ ។ ដោយពុំចាំបាច់គិតពីច្បាប់ដែលអាចផ្តល់កិច្ចការពារដល់ជនរងគ្រោះ ដោយអំពើហិង្សាបាននោះ ការអប់រំអាចជាឧបករណ៍មួយដែលមានប្រសិទ្ធិភាពខ្លាំងទប់ស្កាត់ហិង្សាទាំងនេះ ។ ពេលណាដែលស្ត្រីយល់ដឹងពីសិទ្ធិរបស់ខ្លួន ពេលនោះគេអាចក្រោកឈរឡើងដើម្បីខ្លួនគេ ហើយពេលណាដែលប្រជាពលរដ្ឋយល់ដឹងពីសិទ្ធិស្ត្រី ពេលនោះគេគោរពស្ត្រី ។

ការអប់រំនគរបាល និងតុលាការអំពីរបៀបអនុវត្ត និងបកស្រាយច្បាប់ក៏ជាផ្នែកមួយដ៏សំខាន់នៅក្នុងដំណើរការនេះ ។ បើកង្វះការណែនាំច្បាស់លាស់ និងការឱ្យតម្លៃនូវអ្វី ដែលច្បាប់បានបង្ហាញនោះ បញ្ហាហិង្សាលើស្ត្រីនៅតែគ្មានការយកចិត្តទុកដាក់ដូចដែលធ្លាប់កើតមានតាំងពីទសវត្សមុនៗដដែល ។

ហិង្សាលើស្ត្រីគឺជាបញ្ហាធ្ងន់ធ្ងរនៅកម្ពុជា ។ រាជរដ្ឋាភិបាលត្រូវតែដោះស្រាយឫសគល់នៃការរើសអើងនៅក្នុងសង្គមដែលបដិសេធស្ត្រីពីកិច្ចការពារដោយច្បាប់ ហើយដែលកំពុងបន្តធ្វើយុត្តិកម្មនូវវដ្ត នៃអំពើហិង្សា ។ ត្រូវទទួលស្គាល់ថាហិង្សាលើស្ត្រីភេទគឺជាបញ្ហាដែលប៉ះពាល់មនុស្សគ្រប់រូបនៅក្នុង សង្គមកម្ពុជា ។